# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## ការិយាល័យធានាគុណភាព




# របាយការណ៍

# ស្តីពីលទ្ធភាពរកការងាររបស់និស្សិត

# ឆ្នាំ២០១៤

**រៀបចំដោយៈ ទង់ ឆវី**

**ឧបត្ថម្ភដោយៈ** Maryknoll Cambodia

បោះពុម្ពដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ខែមករា ២០១៥

ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើឆ្នាំ២០១៤
របស់និស្សិតបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១២

រៀបចំដោយ: លោក វង់ ឆវី
មន្ត្រីការិយាល័យធានាគុណភាព

ខែ មករា ឆ្នាំ២០១៥

www.rupp.edu.kh
**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌទួលគោក ក្រុងភ្នំពេញ ប្រទេសកម្ពុជា
Tel: 855-23-883-640 Fax: 855-23-880-116

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........ - 5 -

មូលន័យសង្ខេប ........ - 6 -

របាយការណ៍សង្ខេប ........ - 8 -

អនុសាសន៍ ........ - 11 -

**១.សេចក្តីផ្តើម** ........ - 13 -

១.១ ប្រវត្តិការសិក្សា ........ - 13 -

**២.អំណានឯកសារ** ........ - 16 -

២.១ ឯកសារទាក់ទងការសិក្សាអំពីលទ្ធភាពស្វែងរកការងារ ........ - 16 -

២.២ សំណួរសម្រាប់ស្រាវជ្រាវ ........ - 18 -

២.៣ សំណួរស្រាវជ្រាវទាក់ទងការសិក្សាពីលទ្ធភាពស្វែងរកការងារ ........ - 18 -

**៣.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ** ........ - 20 -

៣.១ វិធីសាស្ត្រជ្រើសរើសគំរូតាង ........ - 21 -

៣.២ ទំហំគំរូតាង ........ - 21 -

៣.៣ កម្រងសំណួរ ........ - 22 -

៣.៤ ការប្រមូលទិន្នន័យ ........ - 23 -

៣.៥ ការកំណត់លេខកូដនិងបញ្ចូលទិន្នន័យ ........ - 24 -

៣.៦ ការវិភាគទិន្នន័យ ........ - 25 -

**៤.គំហើញនៃការសិក្សាស្រាវជ្រាវ** ........ - 26 -

៤.១ អត្រាចម្លើយទទួលបាន ........ - 26 -

៤.២ ព័ត៌មានពាក់ព័ន្ធអ្នកចូលរួម ........................................................ - 27 -
៤.២.១ ប្រភេទអ្នកចូលរួមផ្តល់ចម្លើយ ........................................................ - 27 -
៤.២.២ អាស័យដ្ឋានបច្ចុប្បន្នរបស់អ្នកចូលរួមផ្តល់ចម្លើយ........................................ - 28 -
៤.៣ បទពិសោធន៍ការសិក្សានិងស្ថានភាពការងាររបស់និស្សិត........................... - 30 -
៤.៣.១ បទពិសោធន៍ក្នុងពេលកំពុងការសិក្សា ................................................ - 30 -
៤.៣.២ ស្ថានភាពការងារនិស្សិតបច្ចុប្បន្នក្នុងឆ្នាំ២០១៤ ....................................... - 31 -
៤.៣.៣ ស្ថាប័នដែលនិស្សិតកំពុងបម្រើការងារក្នុងឆ្នាំ២០១៤ ................................ - 32 -
៤.៣.៤ ម៉ោងធ្វើការនិងប្រាក់បៀវត្ស.................................................................. - 34 -
៤.៤ ការធៀបអត្ថប្រយោជន៍ចំណេះដឹងដែលជួយដល់អាជីព ............................ - 38 -
៤.៥ តើនិស្សិតចាប់ផ្តើមស្វែងរកការងារមានប្រាក់បៀវត្សពេលណា?.................. - 39 -
៤.៥.១ វិធីសាស្ត្រស្វែងរកការងារ ........................................................................ - 40 -
**៥.ទំនាក់ទំនងគុណវុឌ្ឍិនិងទីផ្សារការងារ**.................................................. - 42 -
៥.១ ចំណេះដឹងនិងជំនាញ........................................................................... - 42 -
៥.២ ការបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ..................................... - 44 -
**៦.បញ្ហាប្រឈមនិងដែនកំណត់របស់ការសិក្សា**.............................................. - 46 -
**៧.សេចក្តីសន្និដ្ឋាន**...................................................................................... - 47 -
ឧបសម្ព័ន្ធទី១៖កម្រងសំណួរស្ទង់មតិ............................................................. - 50 -
ឯកសារយោង.......................................................................................... - 61 -

## បញ្ជីតារាងទិន្នន័យ

តារាងទី១៖ ចម្លើយទទួលបានតាមជំនាញ....................................................២៦

តារាងទី២៖ការប្រៀបធៀបអំពីបទពិសោធន៍ធ្វើការងារ......................................៣១

តារាងទី៣៖ការបរិយាយអំពីស្ថានភាពការងារបច្ចុប្បន្ន២០១៤.............................៣៤

តារាងទី៤៖ការប្រៀបធៀបប្រាក់ខែនិងសញ្ញាបត្រ.............................................៣៦

តារាងទី៥៖ទស្សនៈនិស្សិតលើកម្មវិធីសិក្សានឹងទំនាក់ទំនងអាជីព.......................៤២

## បញ្ជីរូបតារាង


រូបតាងទី១៖ **ភេទអ្នកចូលរួមផ្តល់សម្ភាសន៍.................................................២៧**

រូបតាងទី២៖ **ស្ថានភាពគ្រួសារ.......................................................................២៨**

រូបតាងទី៣៖ **ប្រភេទអ្នកចូលរួមផ្តល់សម្ភាសន៍.............................................២៨**

រូបតាងទី៤៖ **អាស័យដ្ឋាន និងកន្លែងធ្វើការបច្ចុប្បន្ន.......................................២៩**

រូបតាងទី៥៖ **ការប្រៀបធៀបអំពីស្ថានភាពការងារបច្ចុប្បន្ន២០១៤.......................៣៣**

រូបតាងទី៦៖ **ទស្សនៈនិស្សិតអំពីចំណេះដឹងនិងអាជីព.....................................៣៩**

រូបតាងទី៧៖ **វិធីសាស្រ្តស្វែងរកការងារសំខាន់ៗ.............................................៤១**

# សេចក្តីថ្លែងអំណរគុណ

ផ្នែកធានាគុណភាពរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សូមថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅចំពោះអង្គការ Maryknoll NGO ជាពិសេសដល់បណ្ឌិត Luise Ahrens ដែលបានផ្តល់ជាថវិកា សម្រាប់ការសិក្សាអំពីលទ្ធភាពស្វែងរកការងាររបស់និស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០១២។

ការរួមចំណែកដ៏ធំធេងរបស់បងស្រីបណ្ឌិត មិនគ្រាន់តែជួយដល់ផ្នែកគុណភាពឱ្យសម្រេចភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យប៉ុណ្ណោះទេ គឺថែមទាំងបានជួយធ្វើឱ្យសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ទទួលបានព័ត៌មានស្តីពីប្រសិទ្ធិភាពនៃការបណ្តុះបណ្តាលរបស់ខ្លួននាឆ្នាំកន្លងមកទៀតផង ។ ប្រសិនបើមិនមានថវិកាទ្រទ្រង់ការស្រាវជ្រាវនេះទេ លទ្ធផលនៃការសិក្សានេះមិនអាចលេចចេញជារូបរាងបានឡើយ ។ បន្ថែមលើនេះផងដែរ ផ្នែកធានាគុណភាព សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះផ្នែកពាក់ព័ន្ធនានារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញទាំងអស់ ជាពិសេសចំពោះការិយាល័យសិក្សាដែលបានសហការយ៉ាងជិតស្និទ្ធ និងបានផ្តល់ព័ត៌មានសម្រាប់ទាក់ទងនិស្សិត ហើយសូមអរគុណចំពោះក្រុមនិស្សិតដែលបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១២ បានយល់ព្រមផ្តល់ការសម្ភាសតាមទូរស័ព្ទ ។

# មូលន័យសង្ខេប

គោលបំណងចំបងនៃការសិក្សាស្រាវជ្រាវនេះ គឺសំដៅស្វែងរកចម្លើយមួយចំនួន ដែលឆ្លើយតបទៅនឹងចំណោទសំណួរស្រាវជ្រាវ ពាក់ព័ន្ធនឹងគុណវុឌ្ឍិរបស់សាកលវិទ្យាល័យដែលបានជួយនិស្សិតដែលបញ្ចប់ការសិក្សារួចហើយ ឱ្យទទួលបានការងារមួយធ្វើសមស្រប។ សំណួរដែលពាក់ព័ន្ធការសិក្សាស្រាវជ្រាវនេះរួមមាន៖ សំណួរថាតើសាកលវិទ្យាល័យបានជួយនិស្សិតឱ្យទទួលបានការងារមួយតាមរបៀបណា តើនិស្សិតដែលបញ្ចប់ការសិក្សារួចហើយនោះ ត្រូវរង់ចាំពេលវេលាមួយយូរប៉ុន្មានដែរមុននឹងទទួលបានការងារមួយ តើពួកគាត់កំពុងធ្វើការងារអ្វីខ្លះ តើបញ្ហាភេទជាចំណោទប៉ះពាល់ដល់លទ្ធភាពរកការងារធ្វើរបស់និស្សិតដែរទេ តើការងាររបស់ពួកគាត់ផ្ដល់ប្រាក់បៀវត្សក្នុងកម្រិតណា តើជំនាញដែលទទួលបាន ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញអ្វីខ្លះពាក់ព័ន្ធការងាររបស់និស្សិត ហើយថាតើនិស្សិតពេញចិត្តការរៀនសូត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងកម្រិតណា តើគុណវុឌ្ឍិរបស់សាកលវិទ្យាល័យនេះបានផ្ដល់ឱកាសឱ្យនិស្សិតរៀនពេញមួយជីវិតបែបណា? ដើម្បីបំបែកចម្ងល់ទាំងនោះ ការសិក្សាស្ដីអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ ២០១២ ត្រូវបានធ្វើឡើងដោយផ្អែកជានាគុណភាពក្នុងឆ្នាំ២០១៤ ដើម្បីបញ្ជាក់និងផ្ទៀងផ្ទាត់ប្រសិទ្ធភាពនៃការបណ្ដុះបណ្ដាល។ ការសិក្សានេះ បានធ្វើការតាមដានទៅលើក្រុមនិស្សិតអាហារូបករណ៍ និងសិក្សាបង់ថ្លៃ សរុបចំនួន៥៦៥នាក់ ក្នុងចំណោមគំរូតាង៩៣២នាក់ដែលបានជ្រើសតាមការគណនាគំរូតាងនៃស្ថិតិសរុបរបស់និស្សិតដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យក្នុងឆ្នាំ២០១២ ។ អ្នកចូលរួមទាំងនោះ ត្រូវបានសម្ភាសតាមរយៈទូរស័ព្ទ ហើយយើងបានទាក់ទងពួកគាត់ម្នាក់ៗយ៉ាងតិចពីរដង ដើម្បីទទួលបានព័ត៌មានមួយពេញលេញដែលឆ្លើយតបទៅនឹងកម្រងសំណួរពាក់ព័ន្ធអំពីស្ថានភាពការងារបច្ចុប្បន្នរបស់ពួកគាត់ ។ លទ្ធផលនៃការសិក្សាដែលរកឃើញដោយផ្អែកជានាគុណភាព

បានបង្ហាញលទ្ធផលសរុបថាៈ ក្រុមនិស្សិតដែលបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១២កន្លងមក ទទួលបានការងារធ្វើ៨៦,៤ភាគរយ(៨៦.៤%) នៅក្នុងឆ្នាំ២០១៤ បន្ទាប់ពីចាកចេញពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញអស់រយៈពេល១២ខែ ចំណែកអ្នកដែលនៅសេសសល់កំពុងតែបន្តការសិក្សានិងខ្លះទៀតកំពុងស្វែងរកការងារដែលគេពេញចិត្ត ។ តាមការឆ្លើយរបស់អ្នកចូលរួមផ្តល់សម្ភាសន៍បានប្រាប់ឱ្យដឹងថា ពួកគាត់អាចទទួលប្រាក់បៀវត្សចាប់ពី ១00ដុល្លារ រហូតដល់២000ដុល្លារ ក្នុងមួយខែ ហើយអ្នកដែលរស់ក្នុងទីក្រុងមានឱកាសច្រើន និងរកប្រាក់បានច្រើនជាងអ្នកនៅតាមជនបទនិងបណ្តាខេត្ត ។ ទាក់ទងនឹងបំណងចង់ការបន្តការសិក្សានាពេលអនាគត យើងទទួលបានចម្លើយ៤៥,៣ភាគរយពីអ្នកចូលរួមសម្ភាសន៍ថាចង់វិលមកបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញវិញ។ ឆ្លងតាមការសិក្សានេះ យើងអាចសន្និដ្ឋានថា សាកលវិទ្យាល័យភូមិន្ទភ្នំពេញគួរបើកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដែលទាក់ទងតម្រូវការទីផ្សារការងារបន្ថែមទៀត ដោយត្រូវរៀបចំឱ្យមានការសិក្សាលើទីផ្សារការងារមួយច្បាស់លាស់ ។

# របាយការណ៍សង្ខេប

ការសិក្សានេះធ្វើឡើង ក្នុងគោលបំណងស្វែងយល់ឱ្យបានច្បាស់អំពីលទ្ធភាពស្វែងរកការងាររបស់និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំសិក្សា២០១២។ដើម្បីសិក្សាលើការងារនេះ យើងត្រូវរង់ចាំពីរឆ្នាំក្រោយពេលនិស្សិតបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានជាតិអប់រំ(NIE) ពោលគឺចាំរហូតដល់និស្សិតបានបញ្ចប់ការសិក្សាផ្នែកវិក្រិតការនិងគរុកោសល្យ ហើយចេញទៅប្រកបកិច្ចការ ។ គោលបំណងចំបងនៃការសិក្សានេះផ្តោតទៅលើលទ្ធភាពទទួលបានការងារធ្វើ និងស្ថានភាពដែលធ្វើការវិធីដែលក្រុមនិស្សិតស្វែងរកការងារ និងពេលវេលាដែលអាចរកបានការងារមួយធ្វើ និងចង់ដឹងថាតើមុខវិជ្ជាថ្នាក់បរិញ្ញាបត្រដែលបានបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានការពាក់ព័ន្ធនឹងជំនាញនិងជួយសម្រួលដល់អាជីពរបស់ពួកគាត់បែបណា ។

ការស្រាវជ្រាវនេះ គឺផ្តោតទៅលើក្រុមនិស្សិតអាហារូបករណ៍ និងសិក្សាបង់ថ្លៃសរុបចំនួន១៤៥០នាក់ ហើយយើងបានជ្រើសរើសយកគំរូតាង៥៧០នាក់ ប៉ុន្តែទីបំផុតអ្នកចូលរួមក្នុងការសិក្សានេះពេញលេញមានត្រឹមចំនួន៥៦៥នាក់តែប៉ុណ្ណោះ ។ ក្នុងចំណោមអ្នកចូលរួមសម្ភាសន៍ទាំង៥៦៥នាក់នោះ គឺមានបុរស៦៦ភាគរយ(៦៦%) និងស្ត្រី៣៤ភាគរយ(៣៤%) និស្សិតអាហារូបករណ៍៣៣,៣% និងសិក្សាបង់ថ្លៃ៦៦,៧%។ ក្នុងចំណោមអ្នកទាំងនោះមានអាយុចាប់ពី២៤ឆ្នាំដល់២៨ឆ្នាំ មានចំនួន៩៣,៥% ហើយនៅលីវ ៨២,៧%។ អ្នកចូលរួមឆ្លើយសំណួរភាគច្រើន (៦៥,៧%) រស់នៅនិងធ្វើការក្នុងទីក្រុងភ្នំពេញ ចំណែក ៣៤,៣%ទៀតកំពុងរស់នៅនិងធ្វើការតាមបណ្តាខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ ការសិក្សាបានបន្តឱ្យដឹងទៀតថានិស្សិតភាគច្រើន(៩៦,១%) ប្រើពេលប្រហែលជា១២ខែទើបទទួលបានការងារមួយសមបំណង។ សរុបជារួម ក្នុងចំណោមអ្នកមានការងារធ្វើ៨៦,៤% គឺមាន៣៦,៥%បានធ្វើការនៅតាមក្រុមហ៊ុនឯកជន ១៧,៣%ធ្វើ

ជាគ្រូបង្រៀនក្នុងវិស័យអប់រំសាធារណៈក្នុងក្របខណ្ឌរដ្ឋ ១៥%មានអាជីពនិងជំនួញផ្ទាល់ខ្លួន ១៣,៥%ទៀតធ្វើការជាមន្ត្រីរាជការនៅតាមស្ថាប័ននានារបស់រដ្ឋាភិបាល ៩,៦%ធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល និង៧,៣%ធ្វើជាគ្រូបង្រៀនក្នុងវិស័យអប់រំសាធារណៈផ្នែកឯកជន។

ក្នុងន័យនេះយើងអាចទាញការសន្និដ្ឋានជារួមអំពីឱកាសស្វែងរកការងារសម្រាប់និស្សិតដែលទើបបញ្ចប់ការសិក្សា និងទំនាន់ទំនងការអប់រំនៅឧត្តមសិក្សាជាមួយទីផ្សារការងារ ក៏ដូចជាតម្រូវការទីផ្សារការងារក្នុងបរិបទប្រទេសកម្ពុជា។ ការសន្និដ្ឋានសំខាន់ៗដែលឆ្លើយតបនឹងកម្រងសំណួរដែលពាក់ព័ន្ធជាមួយការសិក្សាស្រាវជ្រាវនេះរួមមាន៖

សាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅតែជាទីកន្លែងផ្តល់ទំនុកចិត្តដល់សាធារណជនក្នុងការជ្រើសរើសការសិក្សាកម្រិតឧត្តម។ តាមការផ្តល់ចម្លើយរបស់និស្សិតដែលបានចាកចេញពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានឱ្យដឹងថាពួកគាត់មានឱកាសទទួលបានការងារច្រើន បើទោះបីមានបទពិសោធន៍តិចតួចឬក៏គ្មានបទពិសោធន៍មុនពេលបញ្ចប់ការសិក្សាក៏ដោយ។ ជាឧទាហរណ៍ អ្នកដែលធ្លាប់មានការងារក្រៅម៉ោង [១] ពេលកំពុងសិក្សាបានផ្លាស់ទៅទទួលការងារពេញម៉ោង [២] រីឯអ្នកមិនមានបទពិសោធន៍ការងារ ក៏អាចរកការងារក្រៅម៉ោង ឬការងារពេញម៉ោង ក្រោយពេលបញ្ចប់ការសិក្សាបានដែរ។

បន្ថែមលើសពីនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានរួមចំណែកផលិតធនធានអ្នកបម្រើការខាងផ្នែកអប់រំប្រកបដោយសមត្ថភាពនិងគុណភាព ដើម្បីជួយបំពេញតម្រូវការរបស់សង្គមបច្ចុប្បន្ន ហើយភាគច្រើននៃអ្នកទាំងនោះ កំពុងបំរើការស្ទើរគ្រប់អាជីពតួយ៉ាងដូចជា វិស័យអប់រំសាធារណៈនិងឯកជន អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ននានារបស់រដ្ឋាភិបាល និងអាជីពនានាក្នុងវិស័យឯកជន។

---

[១] ការងារក្រៅម៉ោងគឺការងារដែលទទួលបានប្រាក់កម្រៃទៅតាមម៉ោង ឬកិច្ចសន្យា

[២] ការងារពេញម៉ោងគឺការងារដែលទទួលបានប្រាក់បៀវត្សប្រចាំខែទៀងទាត់

និស្សិតដែលទទួលបានបរិញ្ញាបត្រជំនាញល្អៗពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញគឺមានឱកាសល្អៗក៏ច្រើនណាស់ដែរ ក្នុងការចាប់យកអាជីព ហើយភាគច្រើនអាចរកបានការងារល្អដែលខ្លួនពេញចិត្តក្នុងរយៈពេលមួយឆ្នាំក្រោយពីបានបញ្ចប់ការសិក្សារួច។ ក្នុងទិន្នន័យអង្កេតនោះបង្ហាញថា និស្សិតភាគច្រើនទទួលបានការងារធ្វើក្នុងវិស័យឯកជនគឺអាចមានប្រាក់បៀវត្សខ្ពស់។

បន្ថែមលើសមត្ថភាពនិងចំណេះដឹងដែលទទួលបានពីសិក្សា និស្សិតត្រូវតែមានឥរិយាបថផ្ទាល់ខ្លួនបន្ថែមទៀតដូចជា មានសមត្ថភាពបត់បែន ចេះទទួលខុសត្រូវ មានទំនុកចិត្តលើខ្លួនឯង ជាមនុស្សគួរឱ្យទុកចិត្តបាន មានសមត្ថភាពដោះស្រាយបញ្ហា មានគំនិតច្នៃប្រឌិត មានឆន្ទៈរៀនសូត្រ ចេះស៊ូទ្រាំការងារស្មុកស្មាញ និងមានសមត្ថភាពជាអ្នកដឹកនាំ។ អាកប្បកិរិយា និងឥរិយាបថបែបនេះត្រូវតែដាក់បញ្ចៀបទៅក្នុងកម្មវិធីនានារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីជួយនិស្សិតឱ្យចេះហាត់ពត់លត់ដំខ្លួនឱ្យបានល្អមុនពួកគាត់ចេញបំរើការងារក្នុងសង្គម។

បើពិនិត្យមើលលើកត្តាភេទវិញ គឺថាទាំងនិស្សិតបុរសនិងស្ត្រីគឺសុទ្ធតែមានឱកាសទទួលបានការងារស្មើៗគ្នាហើយពួកគាត់មានវិធីស្វែងរកការងារធ្វើទៅតាមរយៈការផ្សព្វផ្សាយបណ្តាញសាធារណៈ ការសែត និងព័ត៌មានចុះផ្សាយតាមអ៊ីនធឺណែត។

ក្នុងអត្ថន័យនៃការអប់រំ និស្សិតភាគច្រើនមានការពេញចិត្តចំពោះគុណភាពអប់រំនិងជំនាញ ដែលពួកគាត់ទទួលបានពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

យ៉ាងណាមិញ កម្មវិធីសិក្សាជាច្រើននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅតែឆ្លើយតបទៅនឹងគោលបំណងពីខាងដើម ដែលមានទិសដៅបណ្តុះបណ្តាលគ្រូមធ្យមសិក្សា។ ផ្ទុយទៅវិញ តាមរយៈការសិក្សានេះបានរកឃើញថា ក្រុមនិស្សិតដែលទើបបានបញ្ចប់ការសិក្សាទៅថ្មីៗនេះ កំពុងតែធ្វើការនៅក្នុងស្ថាប័នផ្សេងៗ ច្រើនជាងទៅធ្វើជាគ្រូបង្រៀននៅក្នុងស្ថាប័នអប់រំ។ ដូច្នេះក្នុងបរិបទនេះ គឺចាំបាច់ត្រូវកំណត់ទិសដៅថ្មីសម្រាប់

ការបណ្តុះបណ្តាល ដើម្បីឱ្យសមស្របទៅនឹងស្ថានភាពជាក់ស្តែងនិងតម្រូវការទីផ្សារការងារ ក៏ដូចជាត្រូវផ្តល់ឱ្យនិស្សិតនូវជំនាញទន់(អាកប្បកិរិយានិងឥរិយាបថបុគ្គល)។ ក្នុងនោះសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ចាំបាច់ត្រូវផ្តល់ឱកាសឱ្យនិស្សិតរៀនធ្វើការងារដូចជាហាត់ការ ឬចុះធ្វើកម្មសិក្សាតាមកន្លែងផ្សេងៗដើម្បីជួយឱ្យនិស្សិតមានបទពិសោធន៍ធ្វើការងារខ្លះៗមុនគេចាកចេញពីគ្រឹះស្ថានសិក្សាទាំងស្រុង។

## អនុសាសន៍

អនុសាសន៍និងការផ្តល់យោបល់មួយចំនួនខាងក្រោមគឺផ្អែកទៅលើទិន្នន័យទទួលបានពីនិស្សិតនិងអ្នកផ្តល់ការអប់រំ ។

- ពង្រឹងទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងទីផ្សារ ដោយបង្កើតឱ្យមានសាកលវិទ្យាល័យដៃគូឬដៃគូឯកជនដែលអាចបើកឱកាសឱ្យនិស្សិតនិងនិយោជកមានច្រកសម្រាប់ទំនាក់ទំនងគ្នាបានទូលាយ។ បន្ថែមលើសពីនេះ ការបើករៀបចំពិពណ៌ការងារ ឬកន្លែងហាត់ការ ក៏អាចផ្តល់លទ្ធភាពឱ្យនិស្សិតយល់ដឹងពីតម្រូវការទីផ្សារការងារ ឬការទំនាក់ទំនងទ្វេរភាគីអាចជួយឱ្យគេស្វែងយល់ពីតម្រូវការពីគ្នាទៅវិញទៅមកទាំងទីផ្សារការងារ ទាំងតម្រូវការសិក្សា។
- បង្កើតកម្មវិធីបណ្តុះបណ្តាលថ្មីៗ ស្តីពីជំនាញការងារសម្រាប់និស្សិតមុនចាកចេញពីគ្រឹះស្ថាន ហើយគួរបង្រៀននិស្សិតឱ្យយល់ដឹងពីការងារដំបូង ឬក៏ជួយផ្តល់ជំនាញនិងសមត្ថភាពសម្រាប់ប្រឡូកក្នុងទីផ្សារការងារ។
- គប្បីមានការសិក្សាអំពីក្តីរំពឹងរបស់ក្រុមនិយោជក ដើម្បីប្រមូលផ្តុំគំនិតរបស់អ្នកនិយោជកស្តីអំពីការប្រើប្រាស់ផលិតផលនៃការបណ្តុះបណ្តាលនិងការចូលរួមចំណែករបស់សាកលវិទ្យាល័យ។ ទិន្នន័យដែលរកឃើញអាចប្រើប្រាស់ជាមូល

ដ្ឋានដើម្បីវាយតម្លៃពីតម្រូវការនិស្សិតដែលបញ្ចប់ការសិក្សាថ្មីនិងជួយកម្មវិធីថ្នាក់បរិញ្ញាបត្រ អាចរៀបចំកម្មវិធីសិក្សាបច្ចុប្បន្នឱ្យបានសមស្រប។

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញគួរគាំទ្រជំនាញស្រាវជ្រាវនិងគម្រោងនានាដែលអាចបង្កើតព័ត៌មានពាក់ព័ន្ធកម្មវិធីសិក្សានិងតម្រូវការទីផ្សារការងារ ឬតម្រូវការអនាគតរបស់និស្សិតក្នុងវិស័យអាជីពនានា។
- គប្បីមានការសើររើកម្មវិធីសិក្សាឡើងវិញក្នុងទ្រង់ទ្រាយមួយធំ ដែលផ្តោតសំខាន់ទៅលើតម្រូវការចាំបាច់របស់សង្គមកម្ពុជានិងតម្រូវការទីផ្សារការងារបច្ចុប្បន្ន។ លទ្ធផលសើររើកម្មវិធីសិក្សា អាចនាំទៅរកការបង្កើតមុខជំនាញថ្មីដែលមានទំនាក់ទំនាងជាមួយតម្រូវការទីផ្សារការងារ។ កិច្ចការនេះគប្បីពិចារណាទៅលើការផ្លាស់ប្តូរខ្លឹមសារមេរៀននិងវិធីសាស្ត្របង្រៀនផងដែរ។
- កម្មវិធីសិក្សាចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់ពីលទ្ធផលសិក្សាដែលរំពឹងទុក ឬក៏សមត្ថភាព ជំនាញ អាកប្បកិរិយា និងចំណេះដឹងដែលរំពឹងទុកថានិស្សិតអាចសម្រេចបាន។
- រាល់ការចាត់ចែងការងាររបស់សាកលវិទ្យាល័យគប្បីជំរុញឱ្យមានការចូលរួមយោបល់ឬគំនិតពីក្រុមនិស្សិត ទៅតាមកម្មវិធីសិក្សារបស់ដេប៉ាតឺម៉ង់នីមួយៗ។
- ចាំបាច់ត្រូវថែរក្សាទិន្នន័យនានានៅតាមផ្នែកពាក់ព័ន្ធរបស់សាកលវិទ្យាល័យឱ្យមានប្រសិទ្ធភាពនិងគ្រប់ជ្រុងជ្រោយ។ ទិន្នន័យសំខាន់ៗទាំងនោះ រួមមានឯកសាររបស់គ្រូបង្រៀន បុគ្គលិកការិយាល័យនិងជំនួយការនានា ដៃគូសាកលវិទ្យាល័យ ឬអ្នកពាក់ព័ន្ធ និងព័ត៌មាននិស្សិត។

# ជំពូក ១ សេចក្តីផ្តើម

## ១.១ ប្រវត្តិការសិក្សា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានចាប់ផ្តើមរៀបចំសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតតាំងតែពីឆ្នាំ២០០៤មកម្ល៉េះ។ ការសិក្សានេះបានធ្វើជាទៀងទាត់ក្នុងគោលបំណងជួយសាកលវិទ្យាល័យកំណត់ភាពស៊ីសង្វាក់ ឬភាពខុសគ្នារវាងការបណ្តុះបណ្តាលនិងទីផ្សារការងារ។ ជារឿយៗ តែងតែមានការចោទសួរថាតើសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិង/ឬគ្រឹះស្ថានឧត្តមសិក្សាមួយចំនួនទៀតក្នុងប្រទេសកម្ពុជា សម្រេចជោគជ័យលើលទ្ធផលបង្រៀនដូចដែលរំពឹងទុកដែរឬយ៉ាងណាឬបានរួមចំណែកផលិតនូវធនធានមនុស្សប្រកបដោយសមត្ថភាពជាទីពេញចិត្តដល់សង្គមកម្ពុជាដែរទេ? ដើម្បីឆ្លើយតបរាល់ចម្ងល់ទាំងនោះ ផ្នែកធានាគុណភាពបានការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ ២០១២ ដើម្បីបញ្ជាក់និងផ្ទៀងផ្ទាត់ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលរបស់សាកលវិទ្យា–ល័យនេះ។ ការសិក្សានេះ ក៏មានគោលដៅស្វែងយល់ពីគុណភាពអប់រំនៅឧត្តមសិក្សា និងស្ថានភាពដែលនិស្សិតប្រកបការងារ វិធីដែលក្រុមនិស្សិតស្វែងរកការងារ និងពេលវេលាដែលអាចរកបានការងារមួយធ្វើ និងចង់ដឹងថាតើជំនាញនិងអាជីពរបស់ពួកនិស្សិតមានការពាក់ព័ន្ធនឹងមុខវិជ្ជាដែលបានបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញបែបណា។ បន្ថែមលើសពីនេះ យើងរំពឹងថាការសិក្សាមួយនេះអាចជួយចង្អុលបង្ហាញថាកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រមួយណានៅតែឆ្លើយតបនឹងទីផ្សារបច្ចុប្បន្នហើយរបកគំហើញនៃការសិក្សានេះអាចផ្តល់ជាព័ត៌មានសម្រាប់ការអភិវឌ្ឍនាពេលអនាគតក៏ដូចជា

សម្រាប់ការសិក្សាបន្ត។ ផ្ដើមចេញពីទស្សនៈបែបនេះ យើងបានរៀបចំរបាយការណ៍នេះដូចខាងក្រោម៖

បន្ទាប់ពីរបាយការណ៍សង្ខេប យើងរៀបចំឱ្យមានជំពូកទី១ ដែលរៀបរាប់ពីប្រវត្តិការសិក្សានិងសកម្មភាពមួយចំនួនដែលប្រើប្រាស់សម្រាប់ការសិក្សានេះ និងគោលបំណងនៃការសិក្សាស្រាវជ្រាវ។ ក្នុងជំពូកទី២ គឺជាអំណានឯកសារដែលពាក់ព័ន្ធនឹងការសិក្សានេះនិងការកំណត់សំណួរស្រាវជ្រាវដែលនាំទៅដល់ការសិក្សា។ ជំពូកទី៣ បង្ហាញពីវិធីសាស្ត្រប្រើប្រាស់សម្រាប់ប្រមូលព័ត៌មាននិងការវិភាគទិន្នន័យ។ ជំពូកទី៤ ពិពណ៌នាអំពីរបកគំហើញនៃការសិក្សាស្រាវជ្រាវលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត។ ជំពូកទី៥ បង្ហាញពីទំនាក់ទំនងទីផ្សារការងារនិងការផ្ដល់និទស្សន៍ទៅលើគុណភាពបណ្ដុះបណ្ដាល។ ជំពូកទី៦ បង្ហាញពីបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងការសិក្សានេះ ហើយជំពូកទី៧ គឺជាសេចក្ដីសន្និដ្ឋានដែលផ្អែកទៅលើកម្រងសំណួរស្រាវជ្រាវ។ ចំពោះការផ្ដល់អនុសាសន៍និងយោបល់លើការសិក្សានេះគឺមាននៅក្នុងរបាយការណ៍សង្ខេប។

## ១.២ គោលបំណងនិងកម្មវត្ថុនៃការសិក្សា

គោលបំណងចំបងនៃការសិក្សានេះគឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីលទ្ធភាពទទួលបានការងារធ្វើរបស់និស្សិត របៀបដែលក្រុមនិស្សិតស្វែងរកការងារ និងចង់ដឹងថាតើមុខវិជ្ជាដែលពួកគាត់បានសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានជួយដល់និស្សិតទទួលបានការងារដំបូងបែបណា និងបានជួយដល់ការងារល្អប៉ុណ្ណា។ ជាមួយគ្នានេះដែរ ការសិក្សានេះមានបំណងស្ទង់មតិទៅលើគុណភាពអប់រំដែលផ្ដល់ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមរយៈការទទួលបានការងារនិងជោគជ័យក្នុងវិស័យការងារ។ ដូច្នេះការសិក្សានេះ នឹងត្រូវផ្ដោតទៅលើកត្តាមួយចំនួនដូចខាងក្រោម៖

- ធ្វើការតាមដានដំណើរផ្លាស់ប្តូរពីការអប់រំកម្រិតឧត្តមសិក្សាទៅកាន់កន្លែងការងារ ។
- បង្ហាញពីកត្តាដែលជះឥទ្ធិពលដល់ការងារដូចជា ភេទនិងបទពិសោធន៍ការងារ។
- ប្រៀបធៀបលើជំនាញដែលទទួលបានពីការសិក្សា និងតម្រូវការលក្ខខ័ណ្ឌទីផ្សារការងារដែលរួមចំណែកធ្វើឱ្យនិស្សិតទទួលបានជោគជ័យ។
- វិភាគទំនាក់ទំនងរវាងការអប់រំនៅកម្រិតឧត្តមសិក្សានិងការយល់ដឹងអំពីការងារតាមទីផ្សារដែលបុគ្គលម្នាក់ៗ រំពឹងទុកដូចជា៖ ការពេញចិត្តចំពោះការងារ ការរំពឹងទុកអំពីប្រាក់ចំណូល និងស្ថិរភាពការងារ។
- ស្វែងយល់ពីរបៀបរកការងារធ្វើក្នុងចន្លោះក្រោយពេលបញ្ចប់ការសិក្សា។
- ប្រើប្រាស់បទពិសោធន៍នៃការយល់ដឹង និងទស្សនៈផ្ទាល់ខ្លួនរបស់និស្សិតដែលវាយតម្លៃធនធានសម្ភារៈសិក្សា កម្មវិធីសិក្សា ដើម្បីធ្វើជាមូលដ្ឋានកែលម្អក្នុងពេលអនាគត។
- បង្ហាញចំណុចគន្លឹះដែលនិស្សិតទទួលបានសម្រាប់ការរៀនពេញមួយជីវិត និងបង្ហាញអំពីទស្សនៈនិស្សិតលើគុណភាព នៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។
- ស្វែងរកចំណុចខ្សោយនៃកម្មវិធីសិក្សាដែលត្រូវកែលម្អ ដើម្បីបំពេញឱ្យលទ្ធផលសិក្សាដែលរំពឹងទុក។

# ជំពូក ២ អំណានឯកសារ

អំណានឯកសារដែលពាក់ព័ន្ធនឹងការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើប្រភេទនេះក្នុងបរិបទប្រទេសកម្ពុជាបច្ចុប្បន្ន គឺកម្រប្រទះណាស់ ហើយនៅមានកម្រិតនៅឡើយ ពីព្រោះការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតនៃសាកលវិទ្យាល័យលើកមុនៗ មិនទាន់មានការយកចិត្តទុកដាក់ខ្លាំងនៅឡើយ។ ការផ្តល់ការបរិយាយបែបនេះ គឺដើម្បីបង្ហាញឱ្យឃើញថា អ្នកដែលចាប់អារម្មណ៍ចង់សិក្សាស្វែងយល់បន្ថែមលើបញ្ហានេះក្នុងគោលបំណងផ្សេងៗ គឺអាចជួបប្រទះការលំបាកខ្លាំងណាស់។ រាល់ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតដែលបានស្រាវជ្រាវដោយសាកលវិទ្យាល័យ-ភូមិន្ទភ្នំពេញក្នុងពេលកន្លងមកមិនមានការបោះពុម្ពជាចំហសម្រាប់សាធារណៈជនអាចយល់ដឹងឬយកទៅប្រើប្រាស់ជាទូទៅឱ្យបានទូលំទូលាយនៅឡើយទេ ដូច្នេះការសិក្សាមួយនេះ បានផ្តើមចេញពីបំណងធំមួយ គឺដើម្បីផ្តល់ព័ត៌មានដែលអាចប្រើប្រាស់ជាប្រយោជន៍និងផ្តល់ការយល់ដឹងពីស្ថានភាពពិតជាក់ស្តែងរបស់និស្សិតដែលបានបញ្ចប់ការសិក្សាទាំងឡាយនោះ ។

## ២.១ ឯកសារទាក់ទងការសិក្សាអំពីលទ្ធភាពស្វែងរកការងារ

ការសិក្សាអំពីលទ្ធភាពស្វែងរកការងាររបស់និស្សិតដែលពាក់ព័ន្ធជាមួយការស្ទង់មតិនេះ មានបង្ហាញដូចខាងក្រោម៖

- ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត សាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០០៤ (មិនមានបោះពុម្ព)បានធ្វើឡើងដោយផ្នែក

ធានាគុណភាពដើម្បីតាមដានស្ថានភាពការងាររបស់និស្សិតក្នុងបរិបទប្រទេសប្រទេសកម្ពុជា។ការសិក្សានោះបានវាយតម្លៃទៅលើការផ្តល់ធនធានមនុស្សដែលផលិតដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ហើយរបកគំហើញនៃការសិក្សានោះគឺអាចផ្តល់ជាព័ត៌មានសម្រាប់អ្នករៀបចំគោលនយោបាយនិងគណៈកម្មការរៀបចំកម្មវិធីសិក្សា ដើម្បីធ្វើបច្ចុប្បន្នភាពខ្លឹមសារមេរៀនដែលជួយអ្នកបញ្ចប់ការសិក្សាឱ្យមានលទ្ធភាពទទួលការងារបានច្រើនក្នុងទីផ្សារការងារ។

- របាយការណ៍ស្តីពីការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតវិទ្យាស្ថានភាសាបរទេសក្នុងឆ្នាំ២០០៤ (មិនមានបោះពុម្ព)បានធ្វើឡើងដោយវិទ្យាស្ថានភាសាបរទេសដើម្បីកំណត់ប្រសិទ្ធភាពកម្មវិធីសិក្សាភាសាអង់គ្លេសដែលគ្រប់គ្រងដោយបុគ្គលិកក្នុងស្រុក។ ការសិក្សានោះមានគោលបំណងផ្តល់ព័ត៌មានដើម្បីធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សានិងខ្លឹមសារមេរៀនដើម្បីជួយនិស្សិតឱ្យមានលទ្ធភាពក្នុងបម្រែបម្រួលតម្រូវការទីផ្សារ។
- របាយការណ៍ស្តីពីការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០១០(ប្រើប្រាស់សម្រាប់អ្នកពាក់ព័ន្ធផ្ទៃក្នុង) បានធ្វើការសិក្សាដោយផ្នែកធានាគុណភាពដើម្បីផ្តល់ជាព័ត៌មានសម្រាប់អ្នកគ្រប់គ្រងកម្មវិធីសិក្សានិង/ឬប្រធានដេប៉ាតឺម៉ង់អំពីការទាមទាររបស់និស្សិតនិងធ្វើបច្ចុប្បន្នភាពលើការគ្រប់គ្រងស្តីពីអាជីពក្នុងស្ថានភាពទីផ្សារការងារនៅកម្ពុជា។ របកគំហើញនៃការសិក្សានោះគឺអាចជាមូលដ្ឋានសម្រាប់ពង្រីកកម្មវិធីដែលមានស្រាប់ក្នុងសាកលវិទ្យាល័យ ឬរៀបចំបើកកម្មវិធីសិក្សាថ្មីៗ ដែលស្រមតាមការប្រែប្រួលតម្រូវការទីផ្សារ។

- របាយការណ៍ស្តីពីការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០១២ ដែលសាធារណៈជនអាចរកបាន គឺរៀបចំដោយផ្នែកធានាគុណភាព ដើម្បីបញ្ជាក់អំពីគុណភាពអប់រំនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ(រដ្ឋ)។ របកគំហើញនៃការសិក្សានោះគឺអាចជួយសាកលវិទ្យាល័យកំណត់អំពីលទ្ធផលសិក្សាដែលរំពឹងទុក ចំណុចខ្លាំងនិងចំណុចខ្សោយនៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ និងទំនាកទំនងរវាងការអប់រំបណ្តុះបណ្តាលជាមួយនឹងតម្រូវការទីផ្សារការងារ។ ដើម្បីបញ្ជាក់អំពីប្រសិទ្ធភាពនៃកម្មវិធីសិក្សានានារបស់សាកលវិទ្យាល័យ ផ្នែកធានាគុណភាពបានធ្វើការសិក្សាស្រាវជ្រាវជាមួយនិស្សិតពីរជំនាន់ ដើម្បីទទួលបានព័ត៌មានសម្រាប់យកមកធ្វើការប្រៀបធៀប។

## ២.២ សំណួរសម្រាប់ស្រាវជ្រាវ

សំណួរសម្រាប់ស្រាវជ្រាវគឺបង្កើតឡើងសម្រាប់ប្រមូលព័ត៌មានសំខាន់ៗ ដែលជួយអ្នកផ្តល់ការអប់រំឱ្យយល់កាន់តែច្បាស់អំពីតម្រូវការចាំបាច់របស់អ្នកពាក់ព័ន្ធនិងតម្រូវការទីផ្សារការងារបច្ចុប្បន្ន។

## ២.៣ សំណួរស្រាវជ្រាវទាក់ទងការសិក្សាពីលទ្ធភាពស្វែងរកការងារ

១. តើមុខវិជ្ជាសិក្សានៅសាកលវិទ្យាល័យជួយនិស្សិតឱ្យទទួលការងារធ្វើបែបណា?

២. តើនិស្សិតប្រើពេលយូរប៉ុន្មាន ដើម្បីរកបានការងារមួយដែលត្រូវតាមជំនាញរបស់ពួកគេ?

៣. តើនិស្សិតកំពុងធ្វើការងារនៅទីណាខ្លះក្រោយពេលបញ្ចប់ការសិក្សា?

៤. តើកត្តាភេទជះឥទ្ធិពលដល់ឱកាសរកការងារនិងអាជីពរបស់និស្សិតបែបណា?

៥. តើនិស្សិតអាចរកប្រាក់ចំណូលពីអាជីពរបស់គេក្នុងកម្រិតណា?

៦. តើនិស្សិតធ្វើការក្នុងកន្លែងមួយដែលមិនត្រូវតាមជំនាញរបស់គេក្នុងកម្រិតយ៉ាងណា?

៧. តើជំនាញអាជីពអ្វីដែលត្រូវការជាចាំបាច់ដើម្បីទទួលបានប្រសិទ្ធភាពនិងជោគជ័យទីផ្សារពលកម្មទំនើប?

៨. តើនិស្សិតពេញចិត្តចំពោះការសិក្សារបស់គេនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងពេលសិក្សាកន្លងមកដែរឬទេ?

៩. តើគុណវុឌ្ឍិរបស់សាកលវិទ្យាល័យផ្តល់ឱ្យនិស្សិតនូវការសិក្សាពេញមួយជីវិតបានច្រើនយ៉ាងណា?

# ជំពូក ៣ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ សំដៅបង្កើតវិធានវាយតម្លៃសកម្មភាពរបស់សាកលវិទ្យាល័យជាប្រចាំ ហើយលទ្ធផលសិក្សានឹងជួយសាកលវិទ្យាល័យឱ្យកំណត់លទ្ធផលសិក្សាដែលរំពឹងទុក ចំណុចខ្លាំងនិងចំណុចខ្សោយនៃកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ និងទំនាក់ទំនងរវាងការអប់រំបណ្តុះបណ្តាលជាមួយនឹងតម្រូវការទីផ្សារការងារ។ យោងទៅលើកត្តាទាំងនេះ វិធីសាស្ត្រដែលនាំទៅរកការឆ្លើយសំណួរស្រាវជ្រាវខាងលើនឹងអាចជួយបង្កើនការយល់ឱ្យកាន់តែច្បាស់ពីលទ្ធភាពរកការងាររបស់និស្សិត។ ផ្អែកលើសំណួរស្រាវជ្រាវទាំងនោះ យើងបានជ្រើសរើសតំណាង១៤៥០នាក់ដែលអាចធ្វើជាគំរូសម្រាប់តាងឱ្យក្រុមនិស្សិតទាំងមូល ពីក្នុងចំណោមក្រុមនិស្សិតអាហារូបករណ៍និងសិក្សាបង់ថ្លៃដែលបានបញ្ចប់ការសិក្សាតាមលក្ខណៈឆ្លាស់។

ដើម្បីប្រមូលទិន្នន័យដែលត្រូវការ យើងបានប្រើប្រាស់វិធីសាស្ត្រតាមបែបស្ថិតិ និងវិធីសាស្ត្រវិភាគអត្ថបទ ដោយប្រើប្រាស់កម្រងសំណួរជាឧបករណ៍សម្រាប់ប្រមូលព័ត៌មាននិងទិន្នន័យ ហើយកម្រងសំណួរដែលប្រើប្រាស់សម្រាប់សម្ភាសក៏បានធ្វើការសាកល្បងដើម្បីប្រាកដថាកម្រងសំណួរទាំងនោះជាឧបករណ៍សម្រាប់ប្រមូលព័ត៌មានដែលចង់បានពិតប្រាកដ។ ក្នុងនោះ ក្រុមអ្នកសម្ភាសន៍ត្រូវបានបណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ ដើម្បីប្រាកដថាពួកគេមានសមត្ថភាពសម្ភាសបានល្អនិងចេះប្រមូលព័ត៌មានដែលចាំបាច់។ ក្នុងពេលដែលពួកអ្នកសម្ភាសន៍ចេញធ្វើសម្ភាសដោយម្ចាស់ការហើយ ផ្នែកធានាគុណភាពបានតាមពិនិត្យយ៉ាងយកចិត្តទុកដាក់ ដើម្បីឱ្យព័ត៌មានដែលប្រមូលបានពីការស្ទង់មតិនេះអាចជាព័ត៌មានដែលជឿទុកចិត្តបាន។

## ៣.១ វិធីសាស្ត្រជ្រើសរើសគំរូតាង

និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យក្នុងឆ្នាំ២០១២មានចំនួន ២៤៧៧នាក់ ហើយលេខទូរស័ព្ទរបស់ពួកគាត់ដែលផ្តល់ដោយការិយាល័យសិក្សាត្រូវបានប្រើប្រាស់ជាគ្រោងសម្រាប់គំរូតាងតាមរយៈបែងចែកជាចំណាត់ថ្នាក់ហើយ ទើបជ្រើសរើសយក១៤៥០នាក់តាមលក្ខណៈឆ្លាស់។ បន្ទាប់មកយើងជ្រើសរើសយកតែគំរូតាង៥៧០នាក់មកសិក្សា ហើយត្រៀមបម្រុង២៥% (ស្មើចំនួន៣៦២នាក់) ទៀតសម្រាប់ជំនួសអ្នកដែលមិនអាចទាក់ទងបានក្នុងហេតុផលណាមួយ។ ដោយហេតុដូច្នេះ គំរូតាងមានទំហំធំជាងតម្រូវការ ដើម្បីជំនួសឱ្យអ្នកដែលជ្រើសរើសជាគំរូតាងរួចហើយ បែរជាដកខ្លួនចេញឬជំនួសឱ្យករណីដែលលេខទូរស័ព្ទមិនអាចទាក់ទងបាន។ យោងទៅលើហេតុផលនេះ វិធីសាស្ត្រជ្រើសរើសគំរូតាងធ្វើឡើងតាមរយៈជួសបន្ថែមឬបំពេញចន្លោះដែលមិនទាន់គ្រប់ ហើយគំរូតាងដែលត្រូវជំនួសអាចមានរួចជាស្រេចនៅពេលណាដែលការខ្វះចន្លោះទាំងនោះអាចកើតឡើង។ ក្នុងចំណោមគំរូតាងដែលបានជ្រើសរើសរួចហើយ គឺយើងអាចទំនាក់ទំនងបានតែចំនួន៥៦៥នាក់ប៉ុណ្ណោះ ក្នុងនោះមានបុរស៦៦% និងស្ត្រី ៣៤% ដែលបានយល់ព្រមឱ្យសម្ភាសពីដើមដល់ចប់។

## ៣.២ ទំហំគំរូតាង

ការប្រើប្រាស់ព័ត៌មានលេខទូរស័ព្ទរបស់និស្សិតមានការលំបាកណាស់ដោយសារតែមានលេខទូរស័ព្ទជាច្រើនបានផ្លាស់ប្តូរដែលធ្វើឱ្យយើងពិបាកពឹងផ្អែកទាំងស្រុងលើចំនួនមួយពិតជាក់លាក់។ ម្យ៉ាងវិញទៀត ចំនួននិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឯកទេសមួយចំនួនតិចពេក មិនអាចធ្វើជាគំរូតាងសម្រាប់ការសន្និដ្ឋានរួម ដោយហេតុដូចនេះពិបាកប្រៀបធៀបលទ្ធផលក្នុងផ្នែកទាំងនោះណាស់។ ប្រសិនបើចង់បង្កើនចំនួនក្នុងឯកទេសនីមួយៗឱ្យបានច្រើនវាអាចជាដំណោះស្រាយមួយ ប៉ុន្តែឱកាសសម្រាប់ការស្រាវជ្រាវ

នេះមានកម្រិតឬអាចខុះ។ ការផ្តល់ហេតុផលនេះ គឺចង់បញ្ជាក់ថាទំហំគំរូតាងដែលបានជ្រើសរើសនិងធ្វើការគណនាយ៉ាងហ្មត់ចត់ដោយផ្អែកលើភាពលំអៀង០,០៥នោះ អាចជាគំរូតាងដែលអាចទុកចិត្តនិងប្រកបដោយសុក្រិតភាពក្នុងការធ្វើជាតំណាងឱ្យអ្នកបានបញ្ចប់ការសិក្សាទាំងមូល។ ចំនួនគំរូតាងរបស់អ្នកចូលរួមដែលបានជ្រើសរើសសម្រាប់ការស្ទង់មតិនេះ គឺជាតួលេខមួយគ្រប់គ្រាន់សម្រាប់បង្ហាញពីឱកាសស្វែងរកការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យកាលពីឆ្នាំ២០១២ ។

## ៣.៣ កម្រងសំណួរ

កម្រងសំណួរដែលប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ បានចែកចេញជា៦ក្រុម ដែលក្រុមនីមួយៗមានគោលបំណងជាក់លាក់។ ក្នុងនោះ កម្រងសំណួរក្រុមទីមួយពាក់ព័ន្ធនឹងព័ត៌មានផ្ទាល់ខ្លួននិស្សិត និងហេតុផលជ្រើសរើសការសិក្សានៅសាកលវិទ្យាល័យ ហើយផ្អែកនេះ ប្រើប្រាស់ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងអាយុ ស្ថានភាពគ្រួសារ និងទីកន្លែងរស់នៅនិងប្រកបការងារបច្ចុប្បន្នរបស់ក្រុមនិស្សិត ។ កម្រងសំណួរក្រុមទីពីរ ប្រើប្រាស់ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងបទពិសោធន៍ការងារមុនពេលនិងក្នុងពេលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្នុងផ្អែកនេះមានគោលបំណងប្រៀបធៀបពីការកើនឡើងនៃលទ្ធភាពរកការងារបច្ចុប្បន្នរបស់និស្សិត។ កម្រងសំណួរក្រុមទីបីប្រើប្រាស់ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងស្ថានភាពការងារបច្ចុប្បន្ន និងការទទួលបានចំណេះដឹងពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញជួយដល់អាជីពរបស់ពួកគេ និងសម្រួលដល់ការស្វែងរកការងារបែបណា។ កម្រងសំណួរក្រុមនេះក៏ប្រើប្រាស់ដើម្បីតាមដានពីទីកន្លែងធ្វើការរបស់និស្សិតប្រាក់បៀវត្ស និងថាតើពួកគេធ្វើការត្រូវតាមជំនាញដែលពួកគេបានសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែរឬទេ ។ កម្រងសំណួរក្រុមទីបួនប្រើប្រាស់ដើម្បីស្វែងយល់ពីវិធីសាស្ត្រនិស្សិតរកការងារធ្វើនិងរយៈពេលដែលពួកគេរង់

ចាំការងារ។ កម្រងសំណួរក្រុមទីប្រាំប្រើប្រាស់ដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងការពេញចិត្តលើគុណភាពនៃមុខជំនាញដែលផ្ដល់ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងទំនាក់ទំនងរវាងចំណេះដឹងដែលទទួលបានថ្មីៗនឹងតម្រូវការទីផ្សារ។ ចំណែកកម្រងសំណួរចុងក្រោយគឺការស្ទាបស្ទង់អំពីបំណងចង់បន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងពេលអនាគត។

## ៣.៤ ការប្រមូលទិន្នន័យ

ដើម្បីប្រមូលទិន្នន័យ ផ្នែកធានាគុណភាពបានចាប់ផ្ដើមប្រមែប្រមូលលេខទូរស័ព្ទរបស់និស្សិតដែលបាន បញ្ចប់ការសិក្សាទាំងអស់ ពីតាមការិយាល័យសិក្សានានារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញតាំងពីខែឧសភា។ នៅចុងខែមិថុនាយើងចាប់ផ្ដើមរើសអ្នកសម្ភាសន៍យកមកបណ្ដុះបណ្ដាល ហើយនៅក្នុងដើមខែកក្កដា យើងបានយកកម្រងសំណួរទាំងនោះទៅប្រើប្រាស់សាកល្បងមុននឹងត្រូវយកទៅអនុវត្តក្នុងការប្រមូលព័ត៌មាននិងដើម្បីធានាថាលទ្ធផលដែលប្រមូលបានអាចបំពេញតាមគោលបំណងនៃការសិក្សានិងរបកគំហើញដែលអាចទទួលយកបានស្របតាមអ្វីដែលយើងចង់ស្វែងរក។ គួរកត់សម្គាល់ថាការស្រាវជ្រាវនេះពឹងផ្អែកទាំងស្រុងទៅលើការធ្វើសម្ភាសតាមទូរស័ព្ទ ពីព្រោះថាបើប្រើប្រាស់សារអេឡិចត្រូនិកគឺមិនអំណោយផលដល់និស្សិតដែលរស់នៅតាមតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជាទេហើយបើប្រើប្រាស់ប្រព័ន្ធប្រៃសណីយ៍កម្ពុជាគឺមិនអាចទុកចិត្តថានឹងទទួលបានចម្លើយមកវិញទេ។ ដោយសារហេតុផលទាំងនោះ អ្នកចូលរួមទាំងនោះ ត្រូវបានសម្ភាសតាមរយៈទូរស័ព្ទ ហើយយើងបានទាក់ទងពួកគាត់ម្នាក់ៗយ៉ាងតិចពីរលើក ដើម្បីទទួលបានព័ត៌មានមួយពេញលេញដែលឆ្លើយតបទៅនឹងកម្រងសំណួរពាក់ព័ន្ធអំពីស្ថានភាពការងារបច្ចុប្បន្នរបស់ពួកគាត់ ចំពោះក្រុមអ្នកសម្ភាសន៍ដែលត្រូវប្រមូលទិន្នន័យគឺសុទ្ធតែជាអ្នកទទួលបានការបណ្ដុះបណ្ដាលយ៉ាងត្រឹមត្រូវអំពីរបៀបកត់

ត្រាទិន្នន័យ ដែលតម្រូវឱ្យបំពេញព័ត៌មានឬគូសចម្លើយរបស់កម្រងសំណួរឱ្យបានពិស្តារទៅតាមការដែលអាចធ្វើទៅបាន។ ដោយអាស្រ័យទៅលើភាពទំនេររបស់អ្នកចូលរួម ការសម្ភាសអាចអូសបន្លាយពេលយ៉ាងតិចបំផុត២០នាទីសម្រាប់អ្នកចូលរួមម្នាក់ៗ។ សំណួរដែលប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ ភាគច្រើនតម្រូវឱ្យអ្នកឆ្លើយផ្តល់និទស្សន៍ពីចំនួន១ដល់៥ ដែលមានន័យថាចំនួន**(១)មិនឯកភាពទាល់តែសោះ** ហើយចំនួន**(៥)**មានន័យថា **ឯកភាពទាំងស្រុង** ចំណែកចម្លើយដែលទទួលបានពីការធ្វើសម្ភាសន៍ជាពាក្យពេចន៍ត្រូវបានកត់ត្រាទុកយ៉ាងប្រុងប្រយ័ត្ន ហើយបន្ទាប់មកបានបំលែងបញ្ចូលក្នុងប្រព័ន្ធ SPSS សម្រាប់ធ្វើការវិភាគ ។

## ៣.៥ ការកំណត់លេខកូដនិងបញ្ចូលទិន្នន័យ

ការប្រមូលទិន្នន័យបានចប់សព្វគ្រប់នៅដើមខែតុលា ហើយបន្ទាប់មកផ្នែកធានាគុណភាពដែលទទួលខុសត្រូវលើការសិក្សានេះជាអ្នកដាក់លេខកូដសម្គាល់ទិន្នន័យ។ នៅពាក់កណ្តាលខែតុលា យើងបានបណ្តុះបណ្តាលក្រុមបញ្ចូលទិន្នន័យអំពីរបៀបបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធ SPSS សម្រាប់ធ្វើការវិភាគ ។ ការបញ្ចូលទិន្នន័យប្រើពេលអស់ជិតបីសប្តាហ៍ហើយបានចប់សព្វគ្រប់នៅបំណាច់ខែតុលា។ លទ្ធផលសិក្សាមានន័យគ្រប់គ្រាន់និងអាចប្រើប្រាស់បាន លុះត្រាតែអ្នកចូលរួមផ្តល់ចម្លើយយល់ព្រមទទួលការសម្ភាសតាំងពីដើមដល់ចប់។ ហេតុដូច្នេះទិន្នន័យដែលបានកត់ត្រាជាលាយល័ក្ខអក្សរត្រូវបំលែងជាតួលេខនិងបែងចែកជាផ្នែកៗ មុននឹងដាក់បញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ ហើយបន្ទាប់មក យើងប្រើប្រាស់ប្រព័ន្ធ SPSS15.0 សម្រាប់ចាត់ចែងនិងធ្វើការវិភាគទិន្នន័យទាំងនោះ។

## ៣.៦ ការវិភាគទិន្នន័យ

នៅដើមខែវិច្ឆិកា ការវិភាគទិន្នន័យបានចាប់ផ្ដើម។ ការងារបន្ទាប់គឺការវិភាគចម្លើយនៃការស្ទង់មតិ។ យើងបានចែកលទ្ធផលនៃការវិភាគទិន្នន័យជាបីចំណែកធំៗ ពោលគឺ ផ្នែកទី១ ជាទិន្នន័យនិស្សិតដែលចូលរួមស្ទង់មតិ ផ្នែកទី២ជាទិន្នន័យវិភាគអំពីទំនាក់ទំនងចំណេះដឹងនិងជំនាញដែលនិស្សិតបានសិក្សាកន្លងមកប្រៀបធៀបនឹងបទពិសោធន៍ការងារបច្ចុប្បន្ន ហើយផ្នែកចុងក្រោយគឺជាការវិភាគលើទស្សនៈនិស្សិតអំពីការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងបទពិសោធន៍ដែលទាក់ទងជំនាញឯកទេសទីផ្សារការងារ។ សូមបញ្ជាក់ថា ៖

- ទិន្នន័យជាតួលេខដែលមាននិទស្សន៍ពីចំនួន១ដល់៥ ត្រូវបានគណនាជាភាគរយក្នុងតារាង ដើម្បីបង្ហាញអំពីទស្សនៈរបស់អ្នកចូលរួម។
- ទិន្នន័យដែលលាយល័ក្ខជាអក្សរត្រូវបានដាក់លេខកូដសម្គាល់ទិន្នន័យ និងចែកទៅតាមក្រុម រួចរាប់ចំនួនទិន្នន័យ តាមការវិភាគ។
- លទ្ធផលដែលវាស់ស្ទង់ពីការពេញចិត្តរបស់អ្នកចូលរួមត្រូវបានបកស្រាយដោយផ្អែកលើភាគរយដែលគណនាតាមប្រព័ន្ធSPSS ។ ចំពោះការបកស្រាយលើសំណួរនីមួយៗគឺផ្អែកទៅលើការកើនឡើងឬថយចុះនៃតួលេខនីមួយៗ។

# ជំពូក ៤ គំហើញនៃការសិក្សាស្រាវជ្រាវ

## ៤.១ អត្រាចម្លើយទទួលបាន

ក្នុងចំណោមលេខទូរស័ព្ទរបស់គំរូតាងទាំង៩៣២នាក់ គឺយើងអាចទាក់ទងបានតែ៥៦៥នាក់ប៉ុណ្ណោះ។ ក្នុងនោះលេខទូរស័ព្ទ៣៨%របស់គំរូតាងមិនអាចទាក់ទងបាន ហើយ១,៣%ទៀត បានសុំដកខ្លួនចេញដោយមូលហេតុផ្ទាល់ខ្លួនផ្សេងៗ។

**តារាងទី១៖ចម្លើយទទួលបានតាមជំនាញ**

| ល.រ | ជំនាញ | គំរូតាង ៥៦៥ |
|---|---|---|
| ១ | គណិតវិទ្យា | ៩,២% |
| ២ | រូបវិទ្យា | ២,៨% |
| ៣ | គីមី | ៦.៥% |
| ៤ | ជីវវិទ្យា | ២,៨% |
| ៥ | កុំព្យូទ័រ | ២៩,៧% |
| ៦ | បរិស្ថាន | ១,៦% |
| ៧ | អក្សរសាស្ត្រខ្មែរ | ៧,៦% |
| ៨ | ភូមិវិទ្យា | ៥,៣% |
| ៩ | ចិត្តវិទ្យា | ១,៩% |
| ១០ | សង្គមវិទ្យា | ៧,៣% |
| ១១ | ទស្សនវិជ្ជា | ២,៨% |
| ១២ | ប្រវត្តិវិទ្យា | ១,១% |
| ១៣ | ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ | ១,៩% |
| ១៤ | ទេសចរណ៍ | ១,២% |
| ១៥ | ភាសាបារាំង | ៤,៤% |
| ១៦ | ភាសាអង់គ្លេស | ៦,២% |
| ១៧ | ភាសាជប៉ុន | ៤,២% |
| ១៨ | ភាសាកូរ៉េ | ៣,២% |
| | សរុប | ១០០% |

## ៤.២ ព័ត៌មានពាក់ព័ន្ធអ្នកចូលរួម

ទិន្នន័យដែលលើកមកវិភាគនេះរួមមាន៖អាយុ ភេទ ស្ថានភាពគ្រួសារ និងទីកន្លែងស្នាក់នៅរបស់អ្នកដែលចូលរួម។

### ៤.២.១ ប្រភេទអ្នកចូលរួមផ្តល់ចម្លើយ

យោងតាមការវិភាគទិន្នន័យដែលបានទទួលតាមរយៈទូរស័ព្ទបង្ហាញឱ្យឃើញថា ការស្ទង់មតិនេះមានអ្នកចូលរួមដែលមានអាយុចាប់ពី២៤ឆ្នាំដល់២៨ឆ្នាំមាន៩៣,៥% ហើយក្នុងចំណោមអ្នកដែលយល់ព្រមផ្តល់ការឆ្លើយតបយ៉ាងពេញលេញជាមួយក្រុមសម្ភាសន៍ មាននិស្សិតប្រុស៦៦% និងនិស្សិតស្រី៣៤% អ្នកនៅលីវមាន៨២,៧% និងបានរៀបការហើយមាន១៦,៨%។ អ្នកដែលចូលរួមក្នុងការស្ទង់មតិនេះច្រើនជាងគេ គឺមានក្រុមនិស្សិតសិក្សាបង់ថ្លៃចំនួន៦៦,៧% និងនិស្សិតអាហារូបករណ៍ចំនួន៣៣,៣%។

រូបតាងទី១៖ **ភេទអ្នកចូលរួមផ្តល់សម្ភាសន៍**



រូបតាងទី២៖ **ស្ថានភាពគ្រួសារ**




រូបតាងទី៣៖ **ប្រភេទអ្នកចូលរួមផ្តល់សម្ភាសន៍**




## ៤.២.២ អាស័យដ្ឋានបច្ចុប្បន្នរបស់អ្នកចូលរួមផ្តល់ចម្លើយ

យោងតាមលទ្ធផលដែលទទួលបានតាមរយៈអ្នកចូលរួមផ្តល់សម្ភាសន៍ក្នុងការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា និសិ្សតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាភូមិន្ទ

ភ្នំពេញក្នុងឆ្នាំ ២០១២ កំពុងតែមានទីលំនៅក្នុងក្រុងភ្នំពេញនិងតាមបណ្ដាលខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមរបកគំហើញបានបង្ហាញថា ក្រោយពេលបញ្ចប់ការសិក្សារួចមាននិស្សិត៨២,៧% បានត្រឡប់ទៅរស់នៅជាមួយក្រុមគ្រួសារនិងសាច់ញាតិរបស់ខ្លួន។ ក្នុងនោះមាន ៦៥,៣% កំពុងរស់នៅនិងធ្វើការក្នុងក្រុងភ្នំពេញ ហើយ២២,១% កំពុងរស់នៅនិងធ្វើការតាមបណ្ដាលទីរួមខេត្តនានា ហើយ១១,៦%ទៀត បានកំពុងរស់នៅនិងធ្វើការតាមតំបន់ជនបទដាច់ស្រយាលក្នុងផ្ទៃប្រទេស។ ផ្អែកលើទិន្នន័យដែលរកឃើញនេះ យើងអាចបកស្រាយថា និស្សិតដែលបានបញ្ចប់ការសិក្សារួចហើយ បានជ្រើសរើសទៅធ្វើការកន្លែងដែលគេមានក្រុមគ្រួសាររស់នៅ ដូច្នេះយើងអាចទាញការសន្និដ្ឋានថា អ្នកដែលទទួលការបណ្ដុះបណ្ដាលបានល្អៗ និងអ្នកដែលក្លាយខ្លួនជាគ្រូមានការអប់រំខ្ពង់ខ្ពស់ភាគច្រើនគឺមានការប្រមូលផ្ដុំរកការងារធ្វើតែក្នុងទីក្រុងច្រើន ជាងទៅធ្វើការតាមបណ្ដាខេត្ត ឬតំបន់ជនបទដាច់ស្រយាល។

រូបតាងទី៤៖ **អាស័យដ្ឋាន និងកន្លែងធ្វើការបច្ចុប្បន្ន**



## ៤.៣ បទពិសោធន៍ការសិក្សានិងស្ថានភាពការងាររបស់និស្សិត

នៅអ្នកចូលរួមបានគិតទៅដល់ផលប្រយោជន៍នៃការអប់រំនិងបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ពួកគាត់៧៣,៨%បានផ្តល់ចម្លើយអះអាងថា ការទទួលបានការងារធ្វើកាន់តែច្រើនគឺអាស្រ័យដោយជំនាញនិងគុណភាពនៃការសិក្សា។ ក្នុងនោះពួកគាត់មានឱកាសរកការងារធ្វើតាំងតែពីនៅក្នុងឆ្នាំទី២មកម្ល៉េះ។

### ៤.៣.១ បទពិសោធន៍ក្នុងពេលកំពុងការសិក្សា

យោងតាមការវិភាគទិន្នន័យបានបង្ហាញឱ្យឃើញថា មុនពេលចូលមកសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមាននិស្សិត១៣%មានការងារធ្វើរួចហើយ។ នៅពេលសួរអំពីលទ្ធភាពរកការងារធ្វើក្នុងអំឡុងពេលដែលកំពុងសិក្សា យើងបានរកឃើញថាចំនួនអ្នកមានការងារធ្វើនេះបានកើនឡើងដល់៤៥,៨%(នៃគំរូតាង៥៦៥) ហើយក្នុងចំណោមអ្នកមានការងារធ្វើទាំងនោះ មាន៣៣% អាចទទួលបានប្រាក់ចំណូលពី ១០០ដុល្លាររហូតដល់១៥០ដុល្លារ ហើយមាន៨% ទៀតមានប្រាក់ចំណូលរហូតដល់៣០០ដុល្លារក្នុងមួយខែ។ ក្នុងចំណោមនិស្សិតបីក្រុមដែលមានឱកាសរកប្រាក់ចំណូលច្រើនលេចធ្លោជាងគេក្នុងអំឡុងពេលកំពុងសិក្សា គឺមានផ្នែកកុំព្យូទ័រ ៣២.៤% ភាសាខ្មែរ ១១,៦% និងនិស្សិតផ្នែកគណិតវិទ្យា១០,៤%។ ប្រភេទការងារដែលនិស្សិតបានធ្វើទាំងនោះ៣១,២% គឺជាការងារប្រភេទក្រៅម៉ោង ។ ផ្អែកលើទិន្នន័យនេះបានបង្ហាញថា ក្រុមនិស្សិតភាគច្រើនកំពុងភ្ជាប់ខ្លួនរបស់គេទៅនឹងទីផ្សារការងារ ហើយព្យាយាមរកបទពិសោធន៍មុនពេលពួកគេទទួលបានការងារអចិន្ត្រៃយ៍មួយ។ នេះគឺជាមោទនភាពមួយរបស់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលទទួលបាន ប៉ុន្តែយើងក៏មានការចាប់អារម្មណ៍ដែរ ព្រោះថាក្នុងចំណោមអ្នកមានការងារធ្វើក្រៅម៉ោងទាំង៣១,២% នោះ គឺមាននិស្សិតដទៃជាច្រើន

បានយកចិត្តទុកដាក់លើការសិក្សា ហើយតើការងារដែលនិស្សិតបានធ្វើទាំងនោះ អាចប៉ះពាល់ដល់ការសិក្សារបស់ពួកគេដែរឬទេ? ការយល់ដឹងអំពីផលប៉ះពាល់ដល់ការសិក្សានិងលទ្ធភាពរកការងារធ្វើក្នុងពេលកំពុងសិក្សា មិនទាន់មានការសិក្សាច្បាស់លាស់នៅឡើយទេ ដូច្នេះការសិក្សាស្វែងយល់អំពីបញ្ហានេះអាចជាកិច្ចការបន្ទាប់ដែលត្រូវសិក្សាស្រាវជ្រាវបន្ថែមទៀត។

តារាងខាងក្រោមបង្ហាញពីការប្រៀបធៀបសង្ខេបអំពីនិស្សិតដែលមានការងារធ្វើក្នុងពេលកំពុងសិក្សានិងអ្នកចាប់ផ្តើមធ្វើការក្រោយពេលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**តារាងទី២ ៖ ការប្រៀបធៀបអំពីបទពិសោធន៍ធ្វើការងារ**

| ល.រ | បទពិសោធន៍ធ្វើការងារ | ភាគរយ | ប្រភេទការងារ (គំរូតាង៥៦៥) | |
|---|---|---|---|---|
| | | | ពេញម៉ោង | ក្រៅម៉ោង |
| ១ | ក្នុងពេលកំពុងសិក្សា | ៤៥,៨% | ១៣,៥% | ៣១,២% |
| ២ | ក្រោយពេលបានបញ្ចប់ការសិក្សា | ៨៦,៤% | ៧៨,១% | ៥,៧% |

## ៤.៣.២ ស្ថានភាពការងារនិស្សិតបច្ចុប្បន្នក្នុងឆ្នាំ២០១៤

យោងទៅតាមការសម្ភាស យើងបានរកឃើញថានិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១២ រហូតមកដល់ពេលនេះ មាននិស្សិតចំនួន៨៦,៤%នៃគំរូតាង៥៦៥នាក់ គឺជាអ្នកដែលទទួលបានការងារទៀងទាត់នៅតាមស្ថាប័ននានា ហើយអ្នកក្រៅពីនោះបានបន្តការសិក្សាឬបន្តស្វែងរកការងារមួយដែលគេពេញចិត្ត។ ជាធម្មតា និស្សិតត្រូវប្រើពេលប្រហែលជាមួយឆ្នាំ ឬ១២ខែទើបរកឃើញការងារមួយជាក់លាក់ ពីព្រោះថាបើអ្នកដែល

ចង់ក្លាយខ្លួនជាគ្រូបង្រៀន ត្រូវតែឆ្លងកាត់វគ្គបណ្តុះបណ្តាលវិក្រិតការនិងគរុកោសល្យពីវិទ្យាស្ថានជាតិអប់រំ(NIE)ជាមុនសិន ដូច្នេះក្នុងពេលអន្តរកាលដែលនិស្សិតចេញពីសាកលវិទ្យាល័យទៅកាន់ទីផ្សារការងារហាក់ប្រើពេលវេលាមួយវែងគួរសម។ តាមការរកឃើញក្នុងចំណោមអ្នកដែលមានការងារធ្វើទៀងទាត់ គឺមាននិស្សិត៨៧,១%ធ្វើការងារពេញម៉ោង និង៥,៧%ធ្វើការក្រៅម៉ោង។ ប្រការដែលគួរឱ្យមានមោទនភាពនោះ គឺនិស្សិតធ្វើការងារពេញម៉ោង ក្រោយពេលបញ្ចប់ការសិក្សាបានកើនឡើងយ៉ាងខ្ពស់គឺចាប់ពី១៣,៥%ទៅដល់៧៨,១% រីឯនិស្សិតដែលធ្លាប់ធ្វើការងារក្រៅម៉ោងបានថយចុះពី៣១,៣%មកនៅត្រឹមតែ៥,៧%ប៉ុណ្ណោះ។ យើងអាចនិយាយបានថានេះគឺជាកត្តាសត្យានុម័តមួយដែលយើងរំពឹងទុកក្នុងការបណ្តុះបណ្តាល។

### ៤.៣.៣ ស្ថាប័នដែលនិស្សិតកំពុងបម្រើការងារក្នុងឆ្នាំ២០១៤

ផ្អែកតាមទិន្នន័យវិភាគលើលទ្ធភាពស្វែងរកការងារធ្វើបង្ហាញថា អ្នកដែលមានការងារទៀងទាត់ទាំងនោះមាន៣៤,២% ជានិស្សិតផ្នែកអាហារូបករណ៍ និង៦៥,៨%ជានិស្សិតសិក្សាបង់ថ្លៃ។ យោងតាមការវិភាគទិន្នន័យលើប្រភេទការងារបច្ចុប្បន្នបានបង្ហាញថា៖ និស្សិតភាគច្រើន(៣៦,៥%) កំពុងបម្រើការងារផ្សេងៗតាមស្ថាប័នឯកជន ហើយចំនួន១៧,៣%កំពុងបង្រៀននិងបម្រើការក្នុងវិស័យអប់រំក្របខ័ណ្ឌរដ្ឋ ១៥%មានអាជីវកម្មផ្ទាល់ខ្លួន ១៣,៥%កំពុងបម្រើការងារក្នុងស្ថាប័ននានារបស់រដ្ឋាភិបាល ៩,៦% កំពុងធ្វើការឱ្យអង្គការក្រៅរដ្ឋាភិបាល ហើយ៧,៣%បង្រៀននិងធ្វើការងារក្នុងវិស័យអប់រំឯកជន។ បើយើងធ្វើការប្រៀបធៀបជាមួយការស្ទង់មតិកាលពីលើកមុនៗបានបង្ហាញថានិស្សិតដែលបានបញ្ចប់ការសិក្សាហើយទៅធ្វើការក្នុងផ្នែកឯកជននានាមានការកើនឡើង១៤,៤% អ្នកដែលប្រកបអាជីវកម្មផ្ទាល់ខ្លួនមានការកើនឡើង៨,៥% ធ្វើជាគ្រូបង្រៀននិងបម្រើការក្នុងវិស័យអប់រំក្របខ័ណ្ឌរដ្ឋមានការធ្លាក់ចុះ២៦,៧% ធ្វើការជាមួយ

អង្គការមិនមែនរដ្ឋាភិបាលធ្លាក់ចុះ៦,២% និងបម្រើការក្នុងស្ថាប័ននានារបស់រដ្ឋាភិបាល មានការកើនឡើងបន្តិចបន្តួចគឺ ៨,១% ហើយធ្វើជាគ្រូបង្រៀននិងបម្រើការក្នុងវិស័យអប់រំឯកជនមានកំណើនត្រឹមតែ១,៤%ប៉ុណ្ណោះ។

រូបតាងទី៥៖ **ការប្រៀបធៀបអំពីស្ថានភាពការងារបច្ចុប្បន្ន២០១៤**




ដោយឡែកបើយោងតាមការវិភាគទិន្នន័យលើប្រភេទការងារក្រៅម៉ោង យើងបានរកឃើញថា ៖ ចម្លើយដែលអះអាងថាកំពុងធ្វើការងារក្រៅម៉ោងគឺមានតែ៣២ករណីប៉ុណ្ណោះ ហើយក្នុងតួលេខនោះបានបង្ហាញថា មាននិស្សិត៤៣,៨% កំពុងបម្រើការងារក្នុងផ្នែកក្រុមហ៊ុនឯកជននានា ១៨,៨%បានបង្រៀនក្នុងវិស័យអប់រំឯកជន ហើយ ១២,៥%កំពុងធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល។

តារាងទី៣ ៖ ការបរិយាយអំពីស្ថានភាពការងារបច្ចុប្បន្ន២០១៤

| ប្រភេទការងារ | ការងារពេញម៉ោង គំរូតាង៤៤១ | ការងារក្រៅម៉ោង គំរូតាង៣២ | សរុប គំរូតាង ៥៦៥ |
|---|---|---|---|
| ក្រុមហ៊ុនឯកជននានា | ៤០,៤% | ៤៣,៨% | ៣៦,៥% |
| វិស័យអប់រំរដ្ឋ | ១៩% | ១៨,៨% | ១៧,៣% |
| ស្ថាប័ននានារបស់រដ្ឋាភិបាល | ១៧% | 0% | ១៣,៥% |
| អង្គការមិនមែនរដ្ឋាភិបាល | ១០,៧% | ១២,៥% | ៩,៦% |
| វិស័យអប់រំឯកជន | ៧,៥% | ១៥,៦% | ៧,៣% |
| អាជីវកម្មផ្ទាល់ខ្លួន | ៤,៨% | ៣,១% | ៤,៨% |

## ៤.៣.៤ ម៉ោងធ្វើការនិងប្រាក់បៀវត្ស

ចំពោះនិស្សិតដែលមានការងារធ្វើអាចទទួលប្រាក់បៀវត្សចាប់ពី១៥០ដុល្លារ ដល់ ១៥០០ដុល្លារ។ បើពិនិត្យលម្អិត យើងឃើញថាអ្នកដែលទទួលបានប្រាក់ខែចន្លោះពី ១៥០ដុល្លារ ដល់២០០ដុល្លារ មាន២៩% អ្នកដែលអាចមានចំណូលចន្លោះ២៥០ដុល្លារ ដល់៩០០ដុល្លារ មានចំនួន៣៤,៥% ហើយអ្នកដែលទទួលបានប្រាក់ខែរហូតដល់ ១៥០០ដុល្លារ មានចំនួន៥,១% ។ និស្សិតមានការងារពេញម៉ោងភាគច្រើន(៥៥,៨%) ត្រូវធ្វើការជាមធ្យមចាប់ពី៤០ ទៅ៤៨ម៉ោងក្នុងមួយសប្តាហ៍ ចំណែកក្រុមនិស្សិតដែល មានការងារធ្វើក្រៅម៉ោងបន្ថែម២៨,១% ត្រូវធ្វើការជាមធ្យមចំនួន ៨ ទៅ១៦ម៉ោងក្នុងមួយ សប្តាហ៍។

ការប្រៀបធៀបប្រាក់ចំណូលទៅនិងប្រភេទបរិញ្ញាបត្រ យើងរកឃើញថានិស្សិតភាគច្រើន(២០,៧%) ដែលមានបរិញ្ញាបត្រខាងកុំព្យូទ័រអាចទទួលបានប្រាក់ខែខ្ពស់ជាងគេគឺចន្លោះពី១០០០ដុល្លារទៅ១៥០០ដុល្លារ ហើយ២៥%នៃគំរូតាង៤ផ្នែកនេះដដែលអាចរកប្រាក់ចំណូលច្រើនជាង២០០០ដុល្លារក្នុងមួយខែ។ ចំណែកក្រុមនិស្សិតដែលទទួលបានប្រាក់ខែខ្ពស់ដែរគឺនិស្សិតដែលមានបរិញ្ញាបត្រ ភាសាកូរ៉េ១៧,២% ភាសាជប៉ុន ១៨,៨% និងភាសាអង់គ្លេស១៣,៨% អាចទទួលបានប្រាក់ខែចន្លោះពី១០០០ដុល្លារទៅ ១៥០០ដុល្លារក្នុងមួយខែ។ តារាងខាងក្រោមបង្ហាញព័ត៌មានពិស្តារអំពីប្រាក់បៀវត្សប្រចាំខែទៅតាមប្រភេទបរិញ្ញាបត្រ។

## តារាងទី៤ ៖ ការប្រៀបធៀបប្រាក់ខែនឹងសញ្ញាបត្រ

| ឯកទេស | គ្មានចម្លើយ (N=147) | $100-$120 (N=22) | $120-$150 (N=53) | $150-$200 (N=111) | $200-$300 (N=112) | $350-$500 (N=69) | $500-$900 (N=14) | $1,000-$1,500 (N=29) | Total (N=565) |
|---|---|---|---|---|---|---|---|---|---|
| គណិត | 15.60% | 0.00% | 5.70% | 10.80% | 7.10% | 4.30% | 7.10% | 6.90% | 9.20% |
| រូបវិទ្យា | 4.80% | 0.00% | 0.00% | 7.20% | 0.90% | 0.00% | 0.00% | 0.00% | 2.80% |
| គីមី | 8.80% | 9.10% | 1.90% | 13.50% | 4.50% | 1.40% | 0.00% | 0.00% | 6.50% |
| ជីវវិទ្យា | 4.80% | 4.50% | 5.70% | 1.80% | 1.80% | 1.40% | 0.00% | 0.00% | 2.80% |
| កុំព្យូទ័រ | 19.00% | 22.70% | 26.40% | 30.60% | 43.80% | 34.80% | 42.90% | 20.70% | 29.70% |
| បរិស្ថាន | 1.40% | 0.00% | 1.90% | 1.80% | 0.00% | 0.00% | 0.00% | 10.30% | 1.60% |
| អក្សរសាស្ត្រ | 8.20% | 27.30% | 20.80% | 7.20% | 2.70% | 4.30% | 0.00% | 0.00% | 7.60% |
| ភូមិវិទ្យា | 12.20% | 4.50% | 0.00% | 5.40% | 3.60% | 1.40% | 0.00% | 0.00% | 5.30% |
| ចិត្តវិទ្យា | 2.00% | 0.00% | 1.90% | 1.80% | 2.70% | 2.90% | 0.00% | 0.00% | 1.90% |
| សង្គមវិទ្យា | 4.10% | 9.10% | 5.70% | 8.10% | 11.60% | 10.10% | 7.10% | 0.00% | 7.30% |
| ទស្សនវិជ្ជា | 2.00% | 0.00% | 20.80% | 1.80% | 0.00% | 0.00% | 0.00% | 0.00% | 2.80% |
| ប្រវត្តិវិទ្យា | 0.70% | 4.50% | 1.90% | 1.80% | 0.00% | 1.40% | 0.00% | 0.00% | 1.10% |
| ប្រព័ន្ធផ្សព្វផ្សាយ | 1.40% | 0.00% | 3.80% | 0.00% | 1.80% | 2.90% | 0.00% | 10.30% | 1.90% |

| ឯកទេស | គ្មានចម្លើយ (N=147) | $100-$120 (N=22) | $120-$150 (N=53) | $150-$200 (N=111) | $200-$300 (N=112) | $350-$500 (N=69) | $500-$900 (N=14) | $1,000-$1,500 (N=29) | Total (N=565) |
|---|---|---|---|---|---|---|---|---|---|
| ទេសចរណ៍ | 0.00% | 0.00% | 0.00% | 1.80% | 1.80% | 1.40% | 0.00% | 3.40% | 1.10% |
| ភាសាបារាំង | 2.70% | 0.00% | 3.80% | 3.60% | 2.70% | 11.60% | 7.10% | 3.40% | 4.40% |
| ភាសាអង់គ្លេស | 6.10% | 18.20% | 0.00% | 0.90% | 7.10% | 8.70% | 14.30% | 13.80% | 6.20% |
| ភាសាជប៉ុន | 3.40% | 0.00% | 0.00% | 0.90% | 5.40% | 7.20% | 21.40% | 13.80% | 4.20% |
| ភាសាកូរ៉េ | 2.00% | 0.00% | 0.00% | 0.90% | 2.70% | 5.80% | 0.00% | 17.20% | 3.20% |

ការវិភាគបន្តគឺផ្តោតការយកចិត្តទុកដាក់លើបញ្ហាសមភាពដូចជាភេទនិងស្ថានភាពសង្គមសេដ្ឋកិច្ច។ យោងតាមលទ្ធផលវិភាគបានបង្ហាញថា មាននិស្សិតប្រុស៦៦% និងនិស្សិតស្រី៣៤% សុទ្ធតែទទួលបានការងារមួយទៀងទាត់។ ក្នុងចំណោមនោះ ប្រុស ៦៦,៤% និងនិស្សិតស្រី៣៣,៦% ជាអ្នកធ្វើការងារពេញម៉ោង។ សរុបសេចក្តីមក យើងអាចសន្និដ្ឋានបានថា ទាំងបុរសទាំងស្ត្រីគឺមានឱកាសទទួលបានការងារនិងប្រាក់បៀវត្សដូចគ្នា។ គ្មានអ្នកផ្តល់ចម្លើយណាម្នាក់បានលើកពីកង្វល់នៃការរើសអើងភេទឡើយ។

## ៤.៤ ការធៀបអត្ថប្រយោជន៍ចំណេះដឹងដែលជួយដល់អាជីព

ការស្រាវជ្រាវនេះក៏មានគោលបំណងឈ្វេងយល់អំពីទស្សនៈនិស្សិតអំពីទំនាក់ទំនងបទពិសោធន៍ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងការជួយសម្រួលដល់ការងាររបស់ពួកគាត់បច្ចុប្បន្ន និងចង់ឈ្វេងយល់អំពីទស្សនៈនិស្សិតក្នុងការវាយតម្លៃកម្មវិធីសិក្សា។ តាមចម្លើយ៦៨,១%ដែលទទួលបានពីអ្នកចូលរួមសម្ភាសន៍បានអះអាងថាការងារបស់ពួកគាត់ដែលកំពុងធ្វើបច្ចុប្បន្ននេះមានគឺពាក់ព័ន្ធអ្វីដែលពួកគាត់បានសិក្សានៅឯសាកលវិទ្យាល័យ។ យើងបានបញ្ជាក់សួរថាតើជំនាញ បទពិសោធន៍ និងចំណេះដឹងដែលពួកគាត់ទទួលបានពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានសារៈសំខាន់ជួយសម្រួលដល់ការងាររបស់ពួកគាត់បច្ចុប្បន្នបែបណានោះ ពួកគាត់៣១,៧%អះអាងថា **ច្រើនណាស់** និងមានចម្លើយចំនួន២៥,១% បានបញ្ជាក់ថាអ្វីដែលគាត់បានរៀនសូត្រនៅឯសាកលវិទ្យាល័យនោះគឺមានសារៈសំខាន់ជួយសម្រួលដល់ការងារ**ច្រើន** ។ និយាយឱ្យខ្លីយើងអាចទាញការសន្និដ្ឋានថា និស្សិតដែលបានបញ្ចប់ការសិក្សាភាគច្រើនគឺបានទទួលអត្ថប្រយោជន៍ពីការបណ្តុះបណ្តាល ហើយពេញចិត្តការសិក្សានៅសាកលវិទ្យាភូមិន្ទភ្នំពេញ។ ក្នុងន័យនេះ បានបង្ហាញគុណភាពអប់រំនៅសាកលវិទ្យាភូមិន្ទភ្នំពេញរយៈពេលប៉ុន្មានឆ្នាំកន្លងមកមានភាពរីកចម្រើនល្អប្រសើរគួរឱ្យកត់សម្គាល់ ហើយក៏បានជួយ

បំពេញសេចក្តីត្រូវការទាំងនិស្សិតនិងសង្គមផងដែរ។ សរុបសេចក្តីមក គុណវុឌ្ឍិដែលបានផ្តល់ដោយសាកលវិទ្យាល័យគឺបានជួយបង្កើនសមត្ថភាពនិងជំនាញរបស់និស្សិតឱ្យមានការរីកចម្រើន ហើយបានជួយរួមចំណែកផ្តល់ឱកាសឱ្យនិស្សិតមានលទ្ធភាពកាន់តែប្រសើរក្នុងការស្វែងរកការងារបានកាន់តែច្រើនជាងពេលមុនៗ។

រូបតាងទី៦៖ **ទស្សនៈនិស្សិតអំពីចំណេះដឹងនិងអាជីព**




## ៤.៥ តើនិស្សិតចាប់ផ្តើមស្វែងរកការងារមានប្រាក់បៀវត្សរ៍ពេលណា?

តាមការស្ទង់មតិនេះបានបង្ហាញថា ក្រុមនិស្សិតបានចាប់ផ្តើមស្វែងរកការងារនៅពេលដែលពួកគាត់បានបញ្ចប់ការសិក្សា។ ក្នុងចំណោមនោះនិស្សិត៦២,៤% បានឱ្យដឹងថាពួកគាត់បានចាប់ផ្តើមស្វែងរកការងារធ្វើប្រហែលជា១ខែឬ៣ខែក្រោយពេលបញ្ចប់ការសិក្សា។ អំណះអំណាងនេះមិនរាប់បញ្ចូលនិស្សិត១៧.៧%ដែលបានជ្រើសរើសបន្តការសិក្សាវគ្គបណ្តុះបណ្តាលគរុកោសល្យនៅវិទ្យាស្ថានជាតិអប់រំ(NIE)នោះទេ ពីព្រោះថាពួកគាត់ចង់ក្លាយជាគ្រូបង្រៀននៅវិទ្យាល័យ ឬចង់ក្លាយជាមន្ត្រីរាជការរបស់រដ្ឋ។

## ៤.៥.១ វិធីសាស្ត្រស្វែងរកការងារ

ការសិក្សានេះក៏បានតាមដានមើលអំពីវិធីសាស្ត្រស្វែងរកការងារធ្វើដែលនិស្សិតប្រើប្រាស់ សម្រាប់ទទួលបានលើកដំបូងផងដែរ។ យោងតាមការផ្តល់ចម្លើយរបស់អ្នកដែលធ្វើការពេញម៉ោងនិងមានការងារធ្វើក្រៅម៉ោងបានឱ្យដឹងថា ពួកគេមានវិធីសាស្ត្រស្វែងរកការងារធ្វើតាមយន្តការមួយចំនួនដូចជា តាមរយៈការប្រលងក្របខណ្ឌ តាមរយៈទាក់ទងផ្ទាល់ជាមួយគ្រួសារ និងមិត្តភក្តិ ឬអ្នកស្គាល់គ្នា ទាក់ទងដោយផ្ទាល់ទៅកាន់និយោជក ការិយាល័យប្រឹក្សាការងាររបស់សាកលវិទ្យាល័យ សមាគមន៍និស្សិត ការផ្សព្វផ្សាយពាណិជកម្មតាមប្រព័ន្ធសាធារណៈ បង្កើតមុខជំនួញផ្ទាល់ខ្លួន ប្រឡប់ទៅធ្វើការនៅកន្លែងដើម រាវរកព័ត៌មានតាមរយៈអ៊ីនធឺណែត និងទៅធ្វើការនៅកន្លែងដែលធ្លាប់ហាត់ការ។ ចំណែកមួយចំនួនទៀតនៅបន្តកិច្ចការជំនួញជាមួយគ្រួសារដែលធ្លាប់ធ្វើក្នុងពេលកំពុងរៀន និងនៅតែបន្តទោះបីបានរៀនចប់ហើយក៏ដោយ។

តាមការសិក្សាយើងបានរកឃើញថា និស្សិតដែលបានបញ្ចប់ការសិក្សាភាគច្រើនគឺមានការលំបាកក្នុងការទទួលព័ត៌មានអំពីឱកាសការងារ។ ក្នុងនោះពួកគាត់ប្រើប្រាស់ការស្វែងរកព័ត៌មានតាមរយៈសមាគមន៍និស្សិតមាន០,៧% តាមរយៈការិយាល័យប្រឹក្សាការងាររបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានចំនួន១,២%(សេវាផ្នែកនេះនៅថ្មីប្រហែលនិស្សិតមិនទាន់ដឹង)។ ការស្ទង់មតិនេះ បន្តបង្ហាញទៀតថា និស្សិតដែលបានបញ្ចប់ការសិក្សាចំនួន៤៨៨នាក់ស្មើនឹង៨៦,៤%កំពុងធ្វើការងារក្នុងស្ថាប័ននិងគ្រឹះស្ថាននានា(តួលេខនេះរាប់បញ្ចូលទាំងអ្នកមានការងារពេញម៉ោងនិងក្រៅម៉ោង) គឺបានប្រើប្រាស់យន្តការនិងវិធីសាស្ត្រផ្សេងៗ។ វិធីសាស្ត្រដែលនិស្សិតបានប្រើប្រាស់ច្រើនជាងគេមានដូចជា៖

តាមរយៈការប្រឡងក្របខណ្ឌ[3] មានចំនួន៣១% ដែលអាចមានន័យថាជាប្រភេទការងារទទួលបានតាមការប្រកួតប្រជែងចំហហើយមានតម្លាភាពជាង ប្រសិនបើប្រៀបធៀបទៅនឹងអ្នកដែលមានការងារចំនួន២២,១%ដែលទទួលបានតាមរយៈការទាក់ទងផ្ទាល់ជាមួយគ្រួសារ និងមិត្តភក្តិ ឬអ្នកស្គាល់គ្នា។ ចំណែកអ្នកដែលមានការងារ២១,២%ទៀតបានស្វែងរកការងារតាមរយៈអ៊ីនធឺណែត ៨,៣%បានប្រើប្រាស់ការផ្សព្វផ្សាយព័ត៌មានលើក្តារព័តមានសាកលវិទ្យាល័យភូមិន្ទភ្នំពេញ រីឯនិស្សិត៦,៩%បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពាណិជកម្មសាធារណៈ ៤,៦%បានវិលត្រឡប់ទៅធ្វើការនៅកន្លែងហាត់ការកាលពេលកំពុងនៅរៀន ឬកន្លែងធ្វើការពេលមុន និង៣,៩%បានទាក់ទងនិយោជកដោយផ្ទាល់ និងអ្នកប្រើប្រាស់ការិយាល័យប្រឹក្សាយោបល់ របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានចំនួន១,៩%។

រូបតាងទី៧៖ **វិធីសាស្រ្តស្វែងរកការងារសំខាន់ៗ**




*ទិន្នន័យខាងលើបង្ហាញពីការប្រៀបធៀបអំពីវិធីសាស្រ្តស្វែងរកការងារដែលនិស្សិតបានប្រើប្រាស់ក្នុងដំណាក់កាលអន្តរកាលពេលស្វែងរកការងារ។ការប្រឡងក្របខណ្ឌក្នុងទិន្នន័យនេះសរុបទាំងក្រសួងកិច្ចការយោធា*

[3] ការប្រឡងក្របខណ្ឌគឺត្រូវបានប្រកាសជាសាធារណៈនិងបើកចំហសម្រាប់និស្សិតទាំងអស់ដែលមានសមត្ថភាព។ ថ្មីៗនេះរដ្ឋាភិបាលកម្ពុជាបានជ្រើសរើសនិស្សិតឱ្យចូលបំរើការងារជាច្រើនវិស័យ គឺចាប់ពីក្រសួងអប់រំរហូតដល់ស្ថាប័ន របស់រដ្ឋាភិបាល ក្រសួងកិច្ចការស៊ីវិល និងក្រសួងយោធា។ និស្សិតទាំងអស់ដែលបញ្ចប់ការសិក្សាអាចដាក់ពាក្យប្រឡងបានជាច្រើនកន្លែងតាមចិត្តចង់។

# ជំពូក ៥ ទំនាក់ទំនងគុណវុឌ្ឍិនិងទីផ្សារការងារ

## ៥.១ ចំណេះដឹងនិងជំនាញ

យើងបានសុំឱ្យនិស្សិតវាយតម្លៃលើការពាក់ព័ន្ធសមត្ថភាព ចំណេះដឹងនិងជំនាញដែលជួយដល់អាជីពរបស់ពួកគាត់ ហើយបន្ទាប់មកយើងសុំឱ្យពួកគាត់វាយតម្លៃលើកម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញនិងគុណភាពដែលពួកគាត់គិតថាបានជួយក្នុងការងារដោយសារពួកគាត់ទទួលបានចំណេះដឹងពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ តាមការផ្តល់ចម្លើយជារួម ពួកគាត់បានទទួលស្គាល់ថាការបណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានជួយឱ្យគេមានសមត្ថភាពរកការងារមួយសមស្របនិងបំពេញការងារបានល្អ។ តារាងខាងក្រោមបង្ហាញពីការផ្តល់តម្លៃលើបទពិសោធន៍នៃការសិក្សា និងការពេញចិត្តរបស់និស្សិតដែលចូលរួមឆ្លើយ ហើយបានគណនាជាភាគរយទៅតាមនិទស្សន៍នីមួយៗ។

តារាងទី៥៖ **ទស្សនៈនិស្សិតលើកម្មវិធីសិក្សានឹងទំនាក់ទំនងអាជីព**

*(១)មិនឯកភាពទាល់តែសោះ (២)មិនឯកភាព (៣)គ្មានយោបល់*

*(៤)ឯកភាព និង(៥)ឯកភាពទាំងស្រុង*

| **បទពិសោធន៍ការសិក្សានៅសាកលវិទ្យាល័យ(គំរូតាង៥៦៥នាក់)** | **១** | **២** | **៣** | **៤** | **៥** |
|---|---|---|---|---|---|
| ១. មុខវិជ្ជាទាំងអស់ដែលខ្ញុំសិក្សាមានប្រយោជន៍ខ្លាំងណាស់ចំពោះអាជីពរបស់ខ្ញុំ | *2.8* | *6.4* | *8.0* | **49.7%** | **32.4%** |

| | | | | | |
|---|---|---|---|---|---|
| ២. ការសិក្សានៅស.ភ.ភ.ព.បានផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត | *0.7* | *4.8* | *13.8* | **66.4%** | **12.9%** |
| ៣. មុខវិជ្ជាដែលសិក្សានៅស.ភ.ភ.ព. បានជួយតម្រង់ទិសខ្ញុំឲ្យចាប់យកអាជីពបច្ចុប្បន្ន | *1.4* | *5.8* | *11.9* | **61.9%** | **18.2%** |
| ៤. ជំនាញដែលបានពីការសិក្សានៅស.ភ.ភ.ព.មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយការងារដែលខ្ញុំកំពុងធ្វើ | *1.9* | *11.5* | *10.1* | **49.6%** | **26.0%** |
| ៥. ចំណេះដឹងដែលខ្ញុំបានសិក្សាពី ស.ភ.ភ.ព.កំពុងជាតម្រូវការចាំបាច់ក្នុងសង្គមកម្ពុជា | *0.4* | *3.4* | *9.7* | **65%** | **20.9%** |
| ៦. ខ្ញុំពេញចិត្តជាមួយចំណេះដឹងនិងគុណភាពអប់រំដែលខ្ញុំបានទទួល ពី ស.ភ.ភ.ព. | *0.2* | *1.9* | *3.7* | **65.8%** | **27.1%** |
| ៧. ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យខ្ញុំមានឱកាសទទួលបានការងារមួយសមស្រប | *0.9* | *3.2* | *6.2* | **66.7%** | **21.6%** |
| ៨. ខ្ញុំចង់ឲ្យមាននិស្សិតក្រោយៗសិក្សាមុខវិជ្ជាដូចខ្ញុំឲ្យបានច្រើន | *5.1* | *8.3* | *12.0* | **45.8%** | **27.6%** |

## ៥.២ ការបន្តការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ក្នុងគោលបំណងស្វែងយល់ពីការបង្កើនចំណេះដឹងរបស់និស្សិត យើងបានសាកសួរពួកគាត់អំពីការសិក្សាសញ្ញាបត្របន្ត។ យោងតាមទិន្នន័យដែលទទួលបានពីការសម្ភាសនិស្សិតបានបង្ហាញឱ្យឃើញថា មាននិស្សិត២១,៩%ប៉ុណ្ណោះដែលបានកំពុងបន្តការសិក្សា ហើយក្នុងនេះមាននិស្សិត៥,៣%ទទួលបានអាហារូបករណ៍និង១១,២%ទៀតបានបង់ថ្លៃដោយខ្លួនឯង។ ក្នុងចំណោមអ្នកដែលបានបន្តការសិក្សាទាំងនោះមាននិស្សិត ១២,២%បានជ្រើសយកមុខជំនាញដដែល និង៦៦,៤%បានប្តូរទៅសិក្សាមុខវិជ្ជាផ្សេង ដើម្បីបំពេញតាមតម្រូវការការងារទីផ្សារ ឬបង្កើនចំណេះដឹង។ តាមការវិភាគដដែលទៅលើប្រភេទសញ្ញាបត្របានបង្ហាញថា អ្នកដែលបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មាន២,៣% ហើយអ្នកដែលមានបំណងចង់បន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានចំនួន៥១% ហើយមាន១៤,៩% ទៀតមានបំណងចង់បន្តការសិក្សាថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យនេះ។

គួរចាប់អារម្មណ៍សង្កេតមើលថា និស្សិត២,១%ដែលបានបន្តការសិក្សាលើមុខជំនាញផ្សេង[4] មានហេតុផលបញ្ជាក់ថា ចង់បង្កើនចំណេះដឹងលើជំនាញដែលមានស្រាប់ និងចំនួន០,៩% បានលើកឡើងថាចង់មានជំនាញមួយឱ្យសមស្របតាមតម្រូវការទីផ្សារ ចំណែកអ្នកដែលចង់មានជំនាញបន្ថែមដើម្បីផ្លាស់ប្តូរការងារឱ្យប្រសើរជាងបច្ចុប្បន្នមាន ៣,២%។ យ៉ាងណាមិញ ចំពោះអ្នកដែលមិនបានបន្តការសិក្សាបានបង្ហាញពីមូលហេតុមួយចំនួនគួរឱ្យកត់សំគាល់ដូចជា៖

- គ្មានលទ្ធភាព ឬខ្វះខាតឱកាសសម្រាប់បន្តការសិក្សា៣៣,៦% ។
- គ្មានពេលវេលាសិក្សាគ្រប់គ្រាន់ ព្រោះរវល់នឹងការងារបច្ចុប្បន្ន ២៣%។

[4] ការជ្រើសរើសបន្តការសិក្សាលើមុខជំនាញផ្សេងនៅទីនេះសំដៅទៅលើការបន្តការសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រដែលខុសពីមុខជំនាញបរិញ្ញាបត្រដែលទទួលពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- ចង់បានបទពិសោធន៍ការងារឱ្យបានច្រើនមុននឹងបន្តការសិក្សាម្តងទៀត៧,១%។
- មានមូលហេតុទាក់ទងនឹងគ្រួសារនិងតំបន់ដែលខ្លួនរស់នៅ៣,១%។
- ចង់បន្តការសិក្សានៅបរទេស0,៩%។
- រង់ចាំឱកាសទទួលបានអាហារូបករណ៍0,៥%។

# ជំពូក ៦ បញ្ហាប្រឈមនិងដែនកំណត់របស់ការសិក្សា

ការសិក្សាអំពីលទ្ធភាពរកការងាររបស់និស្សិត នេះបានជួបបញ្ហាប្រឈមមួយចំនួនក្នុងការប្រមូលទិន្នន័យ។ ក្នុងបញ្ហាប្រឈមទាំងនោះរួមមានៈ

- បញ្ហាដែលប្រឈមខ្លាំងជាងគេគឺខ្វះព័ត៌មានសម្រាប់ទាក់ទងនិស្សិត។
- ការប្រមូលព័ត៌មានសម្រាប់ទាក់ទងនិស្សិតប្រើពេលវេលាយូរពីព្រោះបញ្ជីឈ្មោះនិស្សិតដែលបានផ្តល់ដោយការិយាល័យសិក្សាភាគច្រើនមានតែឈ្មោះ ហើយប្រសិនបើមានលេខទូរស័ព្ទសម្រាប់ទំនាក់ទំនងគឺលេខជាច្រើនមិនអាចទាក់ទងបាន។ យោងតាមហេតុផលនេះ ការជ្រើសរើសគំរូតាងត្រូវប្រើវិធីសាស្ត្រច្រើនបែបនិងបត់បែន។
- អ្នកចូលរួមផ្តល់សម្ភាសន៍ជាច្រើនលើសលប់មិនព្រមផ្តល់ព័ត៌មានសម្រាប់ទំនាក់ទំនងនិយោជករបស់ពួកគាត់ ដូច្នេះយើងមានការពិបាកស្វែងយល់ពីទស្សនៈនិយោជកទៅលើការបណ្តុះបណ្តាលរបស់សាកលវិទ្យាល័យនិងគុណសម្បត្តិនៃអាកប្បកិរិយារបស់និស្សិតដែលកំពុងធ្វើការឱ្យនិស្សិត។ កង្វះព័ត៌មានទាំងនោះ វាពិបាកផ្ទៀងផ្ទាត់ថាតើធនធានដែលបណ្តុះបណ្តាលដោយសាកលវិទ្យាល័យភូមិន្ទ អាចពេញចិត្តអតិថិជនឬនិយោជកទាំងនោះដែរឬទេ។
- ថវិកាសម្រាប់ការសិក្សានេះមានដែនកំណត់ ដូច្នេះវាប៉ះពាល់ទៅដល់ពេលវេលាប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ ពីព្រោះយើងមិនអាចជួលអ្នកសម្ភាសន៍និងអ្នកបញ្ចូលទិន្នន័យឱ្យបានច្រើននាក់ដើម្បីពន្លឿនការងារនេះ។

# ជំពូក ៧ សេចក្តីសន្និដ្ឋាន

យោងទៅលើរបកគំហើញដែលបានអធិប្បាយខាងលើ យើងអាចទាញការសន្និដ្ឋានអំពីឱកាសស្វែងរកការងារសម្រាប់និស្សិតទើបបញ្ចប់ការសិក្សាដែលធ្វើការងារតាមកន្លែងផ្សេងៗ និងទំនាន់ទំនងគុណវុឌ្ឍិនៅឧត្តមសិក្សាដែលមិនបានជួយនិស្សិតឱ្យទទួលបានការងារល្អៗ។ ខាងក្រោមគឺជាការសន្និដ្ឋានសំខាន់ៗដែលឆ្លើយតបនឹងកម្រងសំណួរដែលពាក់ព័ន្ធជាមួយការសិក្សាស្រាវជ្រាវនេះរួមមាន៖

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅតែជាទីកន្លែងផ្តល់ទំនុកចិត្តដល់សាធារណជននិងអ្នកពាក់ព័ន្ធនានា។ និស្សិតភាគច្រើនដែលបានចាកចេញពីសាកលវិទ្យា-ល័យភូមិន្ទភ្នំពេញ មានឱកាសទទួលបានការងារច្រើន បើទោះបីមានបទពិសោធន៍តិចតួចឬក៏គ្មានបទពិសោធន៍មុនពេលបញ្ចប់ការសិក្សាក៏ដោយ។ ជាឧទាហរណ៍ អ្នកដែលធ្លាប់មានការងារក្រៅម៉ោងពេលកំពុងសិក្សា បានផ្លាស់ទៅទទួលការងារពេញម៉ោង រីឯអ្នកមិនមានបទពិសោធន៍ការងារ ក៏អាចរកការងារក្រៅម៉ោង ឬការងារពេញម៉ោង ក្រោយពេលបញ្ចប់ការសិក្សាបានភ្លាមៗដែរ។
- ជាច្រើនឆ្នាំកន្លងមកនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានរួមចំណែកផលិតធនធានអ្នកបម្រើឱ្យផ្នែកអប់រំប្រកបដោយសមត្ថភាពនិងគុណភាព ដើម្បីបំពេញតម្រូវការរបស់សង្គមបច្ចុប្បន្ន ហើយភាគច្រើននៃអ្នកទាំងនោះ កំពុងបម្រើការស្ទើរគ្រប់អាជីព តួយ៉ាងដូចជាវិស័យអប់រំសាធារណៈនិងឯកជន អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ននានារបស់រដ្ឋាភិបាល និងអាជីពនានាក្នុងវិស័យឯកជន។ ការងារអាជីពបង្រៀនភាគច្រើនគឺជាការងារពេញម៉ោងដែលបានផ្តល់ឱ្យនិស្សិត

កំពុងបម្រើការទាំងនោះទទួលប្រាក់ចំណូលមួយសមរម្យ បើទោះបីប្រាក់នោះនៅមានកម្រិតក៏ដោយ។ ដើម្បីរស់ក្នុងស្ថានភាពជាគ្រូបង្រៀនក្នុងបរិបទកម្ពុជាទៅបាន និស្សិតដែលធ្វើជាគ្រូបង្រៀនភាគច្រើនបានរកការងារក្រៅម៉ោងបន្ថែមដើម្បីមានប្រាក់ចំណូលបំពេញបន្ថែមលើប្រាក់បៀវត្ស។

- និស្សិតដែលទទួលបានបរិញ្ញាបត្រជំនាញល្អៗពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺមានឱកាសល្អៗក៏ច្រើនណាស់ដែរ ក្នុងការចាប់យកអាជីព ហើយភាគច្រើនអាចរកបានការងារអចិន្ត្រៃយ៍ល្អៗដែលខ្លួនពេញចិត្តក្នុងរយៈពេលមួយឆ្នាំក្រោយពីបានបញ្ចប់ការសិក្សារួច។ ក្នុងទិន្នន័យអង្កេតនោះបង្ហាញថា និស្សិតភាគច្រើនដែលធ្វើការងារ ក្នុងវិស័យឯកជនគឺអាចមានប្រាក់បៀវត្សខ្ពស់។
- បន្ថែមលើសមត្ថភាពនិងចំណេះដឹងដែលទទួលបានពីសិក្សាដែលប្រើប្រាស់សម្រាប់បំពេញការងារ និស្សិតត្រូវតែមានគុណសម្បត្តិខាងឥរិយាបថផ្ទាល់ខ្លួនបន្ថែមទៀតដូចជា មានសមត្ថភាពបត់បែន ចេះទទួលខុសត្រូវ មានទំនុកចិត្តលើខ្លួនឯង ជាមនុស្សគួរឱ្យទុកចិត្តបាន មានសមត្ថភាពដោះស្រាយបញ្ហា មានគំនិតច្នៃប្រឌិត មានឆន្ទៈរៀនសូត្រ ចេះស៊ូទ្រាំការងារស្មុគស្មាញ និងមានសមត្ថភាពក្នុងភាពជាអ្នកដឹកនាំ យល់ដឹងពីការងារការិយាល័យគឺជាកត្តាដែលចាំបាច់ខ្លាំងណាស់។ មានការសិក្សាជាច្រើនដែលនិយោជកទទួលស្គាល់ថានិស្សិតកម្ពុជាដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យជាច្រើននាក់ នៅខ្វះជំនាញទន់ភ្លន់ឬឥរិយាបថបុគ្គល។
- បើពិនិត្យមើលលើកត្តាភេទវិញ គឺថាទាំងនិស្សិតបុរសនិងស្រ្តីគឺសុទ្ធតែមានឱកាសទទួលបានការងារស្មើៗគ្នា ហើយពួកគាត់មានវិធីស្វែងរកការងារធ្វើភាគច្រើនគឺស្តាប់ការផ្សព្វផ្សាយតាមបណ្តាញសាធារណៈ ការផ្សាយពាណិជ្ជកម្ម ឬការអានកាសែត និងតាមព័ត៌មានដែលចុះផ្សាយលើទំព័រអ៊ីនធឺណែត។

- ក្នុងអត្ថន័យនៃការអប់រំ និស្សិតភាគច្រើនមានការពេញចិត្តចំពោះគុណភាពអប់រំ និងជំនាញ ដែលពួកគាត់ទទួលបានពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ មាននិស្សិតដែលបានបញ្ចប់ការសិក្សាជាច្រើនយល់ឃើញថា ពួកគាត់អាចទទួលបានការងារមួយដូចគាត់រំពឹងទុកពេលបញ្ចប់ការសិក្សា។ ដើម្បីបំពេញសេចក្តីរំពឹងនេះ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានជួយជំរុញកម្មវិធីសិក្សានានាដោយធ្វើការវាយតម្លៃលើកម្មវិធីសិក្សានិងសិក្សាស្វែងយល់អំពីលទ្ធភាពស្វែងរកការងាររបស់និស្សិតជារៀងរាល់ឆ្នាំ។
- កាលដើមឡើយ កម្មវិធីសិក្សាជាច្រើននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មានទិសដៅបណ្តុះបណ្តាលគ្រូមធ្យមសិក្សា។ ប៉ុន្តែឥឡូវនេះ តាមរយៈការសិក្សាបានរកឃើញថា ក្រុមនិស្សិតដែលទើបបានបញ្ចប់ការសិក្សាទៅថ្មីៗនេះ កំពុងតែធ្វើការនៅក្នុងស្ថាប័នផ្សេងៗ ច្រើនជាងទៅធ្វើជាគ្រូបង្រៀនក្នុងស្ថាប័នអប់រំ។ ដូច្នេះ ក្នុងបរិបទថ្មីនេះ គឺចាំបាច់ត្រូវកំណត់ពីតម្រូវការទីផ្សារការងារនិងកំណត់ទិសដៅថ្មីសម្រាប់ការបណ្តុះបណ្តាល ដើម្បីផ្តល់ឱ្យនិស្សិតនូវជំនាញដែលត្រូវការនិងសមត្ថភាពប្រកួតប្រជែងលើទីផ្សារការងារកម្ពុជានិងការងារទីផ្សារអាស៊ាន។

# ឧបសម្ព័ន្ធទី១៖កម្រងសំណួរស្ទង់មតិ

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

Coding: ____________ ផ្នែកធានាគុណភាព

Phone:______________ កម្រងសំណួរសម្រាប់

ការសិក្សាអំពីលទ្ធភាពស្វែងរកការងាររបស់និស្សិតដែលបញ្ចប់ការសិក្សា

ក្នុងឆ្នាំ២០១២

*ការសិក្សានេះមានគោលបំណងស្ទាបស្ទង់មតិអំពីលទ្ធភាពរកការងាររបស់និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (ស.ភ.ភ.ព.)ក្នុងឆ្នាំសិក្សា២០១១-២០១២ ។លទ្ធផលដែលទទួលបានពីការសិក្សានេះ និងរួមចំណែកធ្វើឲ្យកម្មវិធីសិក្សានៅសាកលវិទ្យាល័យនេះកាន់តែមានភាពប្រសើរ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គម។*

*ប្រសិនបើលោក លោកស្រី អ្នកនាង កញ្ញា មានបំណងចង់ពិភាក្សាលើបញ្ហាណាមួយនៃការស្ទង់មតិនេះ សូមលោកអ្នកទាក់ទងទៅ លោកវង់ ធវី មន្រ្តីធានាគុណភាពរបស់ស.ភ.ភ.ព.តាមរយៈទូរស័ព្ទលេខ០១២២២៩២៧៩ ឬ*

e-mail: quality.assurance@rupp.edu.kh ។

***យើងខ្ញុំសូមសន្យាថានឹងរក្សាការសម្ងាត់រាល់ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក។***

*(ជម្រាបសួរ។ខ្ញុំបាទ នាងខ្ញុំទូរស័ព្ទមកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញជាជំនួយការផ្នែកធានាគុណភាព។*

*សូមជម្រាបសួរលោក(គ្រូ) អ្នកគ្រូ លោកស្រី អំពីព័ត៌មានខ្លះៗដែលទាក់ទងនឹងប្រវត្តិសិក្សារបស់*...........)

*(សូមបំពេញព័ត៌មានខាងក្រោមនេះក្រោយការសម្ភាសន៍ចប់សព្វគ្រប់)*

ឈ្មោះ.....................................................................ភេទ (១) ប្រុស (២) ស្រី

*(សូមបំពេញព័ត៌មានខាងក្រោមនេះពេលធ្វើការសម្ភាសន៍បានសម្រេច)*

អតីតនិស្សិត (១) អាហារូបករណ៍ (២) សិក្សាបង់ថ្លៃ *(សូមគូរវង្វង់ជុំវិញលេខ)*

មុខជំនាញដែលបានសិក្សា ________________________ឆ្នាំបញ្ចប់ (1)២០____

## I.ព័ត៌មានផ្ទាល់ខ្លួន

*សុំទោសខ្ញុំសូមអនុញ្ញាតិសុំសួរអំពីស្ថានភាពគ្រួសាររបស់លោក(គ្រូ) អ្នកគ្រូ លោកស្រីបន្តិច។*

| | |
|---|---|
| សំ.១. *តើសព្វថ្ងៃលោក/អ្នកមានអាយុប្រហែលប៉ុន្មានហើយ?* | .....................ឆ្នាំ |
| សំ.២. *តើសព្វថ្ងៃលោក/អ្នកមានគ្រួសារហើយឬនៅ?*<br>(*សូមអានចម្លើយ*) | (១).........*នៅលីវ*<br>(២).........*រៀបការហើយ*<br>(៣)........មេម៉ាយ/ពោះម៉ាយ<br>(៤)........*លែងលះ*<br>(៥)........មិនអាចប្រាប់បាន |
| សំ.៣. *តើលោក/អ្នកមានសមាជិកក្នុងបន្ទុកប៉ុន្មាននាក់?* | .........................នាក់ |
| សំ.៤. *តើអ្នកកំពុងរស់នៅជាមួយអ្នកណា?*<br>(*សូមអានចម្លើយ*) | (១).........*គ្រួសារខ្លួនឯង*<br>(២).........*ឪពុកម្តាយ*<br>(៣)........បងប្អូន<br>(៤).......*ម្នាក់ឯង* (៥)......*ផ្សេងៗ* |

| | |
|---|---|
| សំ.៥. តើសព្វថ្ងៃអ្នកកំពុងរស់នៅទីណា? | (១)ភ្នំពេញ (បើ**ទីក្រុង**សូមរំលងទៅផ្នែកទី II)<br><br>(២)ខេត្ត........................... |
| សំ.៦. តើទីនោះជាទីប្រជុំជនឬជនបទ? | ប្រជុំជន......(១)     ជនបទ.....(២) |
| សំ.៧. តើកត្តាអ្វីដែលជំរុញលោកឱ្យរៀននៅកម្រិតឧត្តមសិក្សា?<br><br>(សូមអានចម្លើយ) | (១).........គ្រួសារ<br><br>(២).........មិត្តភ័ក្រ<br><br>(៣)........បំណងផ្ទាល់ខ្លួន<br><br>(៤)........តម្រូវការសង្គម |

## II. បទពិសោធន៍ការងារក្នុងពេលកំពុងសិក្សា

| | |
|---|---|
| សំ.៨. តើអ្នកមានការងារធ្វើទេមុនពេលចូលមកសិក្សានៅស.ភ.ភ.ព.? | មាន.....(១)  ទេ........(២) |
| សំ.៩. តើក្នុងកំឡុងពេលកំពុងសិក្សាអ្នកធ្លាប់មានការងារធ្វើទេ? | មាន.........(១)  ទេ........(២)<br><br>(បើ**ទេ**សូមរំលងទៅផ្នែកទី III) |
| សំ.១០. តើពេលនៅស.ភ.ភ.ព.នោះអ្នកធ្វើការងារប៉ុន្មានកន្លែង? | ..................កន្លែង |

| | |
|---|---|
| សំ.១១. ក្នុងចំណោមការងារទាំងនោះតើការងារចុងក្រោយជាការងារអ្វី? | (១) ពេញ (២) ក្រៅម៉ោង ម៉ោង |
| សំ.១២. តើអ្នកទទួលបានប្រាក់បៀវត្សពីការងារនោះទេ? | បាទ/ចាស.....(១)<br>ទេ..(២) (រំលងទៅផ្នែកទី III) |
| សំ.១៣.**សុំអធ្យាស្រ័យ**តើប្រាក់បៀវត្សពីការងារនោះប្រហែលប៉ុន្មានដែរ? | .................ដុល្លារ |

## III.ស្ថានភាពការងារពេលបច្ចុប្បន្ន

| | |
|---|---|
| សំ.១៤.តើសព្វថ្ងៃអ្នកមានការងារមួយធ្វើពិតប្រាកដដែរឬទេ? | បាទ/ចាស.....(១)<br>ទេ........(២) (រំលងទៅផ្នែកទី IV) |
| សំ.១៥. តើការងារអ្នកកំពុងធ្វើមានទំនាក់ទំនងនឹងចំណេះដឹងឬបទពិសោធន៍និងជំនាញដែលអ្នកបានសិក្សានៅស.ភ.ក.ព.ដែរទេ? | បាទ/ចាស.....(១)<br>ទេ...(២) (រំលងទៅសំណួរទី ១៧) |
| សំ.១៦. តើចំណេះដឹងឬបទពិសោធន៍និងជំនាញដែលអ្នកទទួលបានពីការសិក្សានៅស.ភ.ក.ព.មានសារៈសំខាន់ជួយសម្រួលដល់ការងារអ្នកបែបណា? | តិចតួចបំផុត.....(១)<br>តិចតួចដែរ........(២) |

| | |
|---|---|
| (សូមអានចម្លើយ) | ល្មមសមរម្យ........(៣)<br>បានច្រើន........(៤)<br>បានច្រើនណាស់........(៥) |
| សំ.១៧. តើអ្នកកំពុងធ្វើការងារជាប្រភេទបែបណា? | (១) ពេញម៉ោង (២) ក្រៅម៉ោង |
| សំ.១៨. តើលោក/ស្រីកំពុងធ្វើការងារស្ថិតនៅក្នុងស្ថាប័នមួយណា?<br>(សូមបញ្ជាក់បើចម្លើយផ្សេងៗ............................)<br>(សូមអានចម្លើយ) | ១.អប់រំសាធារណៈ ៤.អង្គការ<br>២.អប់រំឯកជន ៥.ក្រុមហ៊ុនឯកជន<br>៣.រដ្ឋាភិបាល ៦.ផ្សេងៗ....... |
| សំ.១៩. តើខ្ញុំអាចសុំព័ត៌មានសម្រាប់ទំនាក់ទំនងស្ថាប័នលោក/ស្រីបានទេ? (សុំលេខទូរស័ព្ទ៖ ______________________) | បាទ/ចាស(១) ទេ........(២) |
| សំ.២០. តើអ្នកបានធ្វើការងារនេះរយៈពេលប៉ុន្មានមកហើយ? | .................ឆ្នាំ .................ខែ |
| សំ.២១. តើអ្នកធ្វើការនេះប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍? | .........................ម៉ោង/សប្តាហ៍ |
| សំ.២២. **សុំអធ្យាស្រ័យ**តើអ្នកទទួលប្រាក់បៀវត្សប្រហែល | ..........................ដុល្លារ/រៀល |

| | |
|---|---|
| ប៉ុន្មានដែរ? | |
| សំ.២៣. ក្រៅពីការងារនេះតើអ្នកមានការងារអ្វីផ្សេងទៀតដែរឬទេ? (**ការងារទី២របស់អ្នក**) | បាទ/ចាស.....(១)<br>ទេ........(២) (រំលងទៅផ្នែកទី IV) |
| សំ.២៤. តើការងារនេះស្ថិតនៅក្នុងស្ថាប័នមួយណា? (**ការងារទី២**)<br>(សូមបញ្ជាក់បើចម្លើយផ្សេងៗ......................................)<br>(សូមអានចម្លើយ) | ១.អប់រំសាធារណៈ<br>២.អប់រំឯកជន<br>៣.រដ្ឋាភិបាល<br>៤.អង្គការ<br>៥.ក្រុមហ៊ុនឯកជន<br>៦.ផ្សេងៗ ............... |
| សំ.២៥. តើខ្ញុំអាចសុំព័ត៌មានសម្រាប់ទំនាក់ទំនងស្ថាប័នលោក/ស្រីបានទេ? (លេខទូរស័ព្ទ៖ ________________________________) | បាទ/ចាស(១) ទេ........(២) |
| សំ.២៦. តើអ្នកបានធ្វើការងារនេះរយៈពេលប៉ុន្មានមកហើយដែរ? | ..............ឆ្នាំ ..............ខែ |
| សំ.២៧. តើអ្នកធ្វើការនេះប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍? | .........................ម៉ោង/សប្តាហ៍ |
| សំ.២៨. ***សុំអធ្យាស្រ័យ***តើអ្នកទទួលប្រាក់បៀវត្សប្រហែល | .........................ដុល្លារ/រៀល |

| | |
|---|---|
| ប៉ុន្មានដែរ? | |

## IV. វិធីសាស្ត្រស្វែងរកការងារ

| | |
|---|---|
| សំ.២៩. ក្រោយពេលបញ្ចប់ការសិក្សាពីស.ភ.ភ.ព.តើអ្នកប្រើរយៈ ពេលយូរយ៉ាងណាដែរ ដើម្បីរកការងារមួយបានធ្វើ? | .....................ខែ ...............ឆ្នាំ |
| សំ.៣០. តើអ្នកធ្លាប់បានប្រើវិធីសាស្ត្រអ្វីខ្លះពេលស្វែងរកការងារ?<br>(ចម្លើយអាចច្រើនជាងមួយ) | ១....ការិយាល័យវិជ្ជាជីវៈស.ភ.ភ.ព.<br>២....ការផ្សព្វផ្សាយរបស់ស.ភ.ភ.ព.<br>៣.....ការប្រឡងក្របខណ្ឌ<br>៤.....សមាគមន៍និស្សិតស.ភ.ភ.ព.<br>៥....គ្រួសារ/មិត្តភក្តិ/អ្នកស្គាល់គ្នា<br>៦....ប្រព័ន្ធផ្សព្វផ្សាយពាណិជ្ជកម្ម<br>៧...ទាក់ទងផ្ទាល់ជាមួយនិយោជក<br>៨....ប្រព័ន្ធអ៊ីនធឺណែត<br>៩....ដំទៃទៀត(សូមបញ្ជាក់)................ |
| សំ.៣១. តើជំនាញដែលអ្នកទទួលបានពីការសិក្សានៅស.ភ.ភ.ព. ផ្តល់ភាពងាយស្រួលឲ្យអ្នកស្វែងរកការងារដែរឬទេ? | បាទ/ចាស.....(១)<br>ទេ........(២) |

## v. ទស្សនៈរបស់និស្សិតអំពីការសិក្សានៅស.ភ.ភ.ព.បទពិសោធន៍ដែលទាក់ទងទីផ្សារការងារ (ផ្នែកសាធារណៈនិងឯកជន)

*តើអ្នកយល់ឃើញយ៉ាងណាដែរចំពោះទស្សនៈខាងក្រោម? សូមបង្ហាញការយល់ឃើញរបស់លោកអ្នកតាមនិទស្សន៍ខាងក្រោម៖*

(១)*មិនឯកភាពទាល់តែសោះ* (២)*មិនឯកភាព* (៣)*គ្មានយោបល់* (៤)*ឯកភាព* និង(៥)*ឯកភាពទាំងស្រុង*

| | | | | | |
|---|---|---|---|---|---|
| សំ.៣២. *មុខវិជ្ជាទាំងអស់ដែលអ្នកសិក្សាមានប្រយោជន៍ចំពោះអាជីពអ្នកខ្លាំងណាស់* | ១ | ២ | ៣ | ៤ | ៥ |
| សំ.៣៣. *ការសិក្សានៅស.ភ.ភ.ព.បានផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត* | ១ | ២ | ៣ | ៤ | ៥ |
| សំ.៣៤. *មុខវិជ្ជាដែលអ្នកសិក្សានៅស.ភ.ភ.ព.បានជួយតម្រង់ទិសអ្នកឲ្យចាប់យកអាជីពបច្ចុប្បន្ន* | ១ | ២ | ៣ | ៤ | ៥ |
| សំ.៣៥. *ជំនាញដែលបានពីការសិក្សានៅស.ភ.ភ.ព.មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយការងារដែលអ្នកកំពុងធ្វើ* | ១ | ២ | ៣ | ៤ | ៥ |
| សំ.៣៦. *ចំណេះដឹងដែលអ្នកទទួលបានពីស.ភ.ភ.ព.កំពុងជាតម្រូវការចាំបាច់ក្នុងសង្គមកម្ពុជា* | ១ | ២ | ៣ | ៤ | ៥ |
| សំ.៣៧. *អ្នកពេញចិត្តជាមួយចំណេះដឹងនិងគុណភាពអប់រំដែលអ្នកបានទទួល ពីស.ភ.ភ.ព.* | ១ | ២ | ៣ | ៤ | ៥ |
| សំ.៣៨. *ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានឱកាសទទួលបានការងារមួយសមស្រប* | ១ | ២ | ៣ | ៤ | ៥ |
| សំ.៣៩. *អ្នកចង់ឲ្យមាននិស្សិតក្រោយៗសិក្សាមុខវិជ្ជាដូចអ្នកឲ្យបានច្រើន* | ១ | ២ | ៣ | ៤ | ៥ |

| |
|---|
| សំ.៤០. តើអ្នកមានមតិអ្វីបន្ថែមអំពីទំនាក់ទំនងរវាងការសិក្សានៅស.ភ.ភ.ព.ទីផ្សារការងារបច្ចុប្បន្ន?<br><br>.............................................................................................................................................<br><br>.............................................................................................................................................<br><br>............................................................................................................................................. |

## VI. បំណងលើការសិក្សាបន្តរបស់អតីតនិស្សិត

| | |
|---|---|
| សំ.៤១. តើអ្នកបាន ឬកំពុងសិក្សាបន្តដែរទេ? | បាទ/ចាស.....(១)<br><br>ទេ........(២) (រំលងទៅសំណួរទី ៤៥) |
| សំ.៤២. តើការសិក្សាបន្តរបស់អ្នកជាប្រភេទបែបណា? | (១) អាហារូបករណ៍ (២) បង់ថ្លៃ |
| សំ.៤៣. តើអ្នកបាន ឬកំពុងបន្តការសិក្សាក្នុងកម្រិតណាដែរ? | ១......បរិញ្ញាបត្ររងដែល<br><br>២..........បរិញ្ញាបត្រ+១<br><br>៣.....ក្រោយឧត្តម(Grad. Dip.)<br><br>៤....បរិញ្ញាបត្រជាន់ខ្ពស់ (Master)<br><br>៥.....បណ្ឌិត (Ph.D.) |

| | |
|---|---|
| សំ.៤៤. តើអ្នកចង់បន្តការសិក្សាលើមុខជំនាញដដែលឬទេ? | បាទ/ចាស.....(១) (រំលងទៅសំ ៤៦)<br>ទេ...(២) (រំលងទៅសំណួរទី ៤៧) |
| សំ.៤៥. ហេតុអ្វីបានជាអ្នកមិនបានបន្តការសិក្សា?<br>.......................................................................................................................................................<br>.......................................................................................................................................................<br>....................................................................................................................................... | |
| សំ.៤៦. តើអ្នកចង់មកបន្តការសិក្សានៅស.ក.ក.ព.ទៀតដែរឬទេ?<br>**(បញ្ចប់កិច្ចសម្ភាសន៍) កុំភ្លេចសម្តែងអំណរគុណ** | (១) បាទ/ចាស (២) ទេ |
| សំ.៤៧. ហេតុអ្វីបានជាអ្នកជ្រើសរើសយកមុខជំនាញផ្សេងទៅវិញ?<br>.......................................................................................................................................................<br>.......................................................................................................................................................<br>....................................................................................................................................................... | |

| | |
|---|---|
| សំ.៤៨. *តើអ្នកចង់មកបន្តការសិក្សានៅស.ក.ក.ព.ទៀតដែរឬទេ?*<br>**(បញ្ចប់កិច្ចសម្ភាសន៍) កុំភ្លេចសម្តែងអំណរគុណ** | (១) *បាទ/ចាស* (២) *ទេ* |

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក(គ្រូ) អ្នក(គ្រូ)ដែលបានចំណាយពេលវេលាដ៏មានតម្លៃឆ្លើយតបនឹងកិច្ចសម្ភាសន៍នេះ។

សូមជូនពរឲ្យលោក(គ្រូ) អ្នក(គ្រូ)មានសុខភាពល្អនិងទទួលបានជោគជ័យក្នុងអាជីព។

# ឯកសារយោង

វ័ន្ត ឆាង "*របាយការណ៍ស្តីពីការសិក្សាលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត*" ផ្នែកធានាគុណភាពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ២០០៤ (មិនមានបោះពុម្ព)

វង់ ឆវី "*របាយការណ៍ស្តីពីការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត*" ផ្នែកធានាគុណភាព សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ២០១០(មិនមានបោះពុម្ព)

វង់ ឆវី "*របាយការណ៍ស្តីពីការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត*" ផ្នែកធានាគុណភាព សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ២០១២

អនាមិក "*របាយការណ៍ស្តីពីការសិក្សាលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត*" វិទ្យាស្ថានភាសាបរទេស សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ២០០៤ (មិនមានបោះពុម្ព)